# បរមត្ថជោតិកៈ

## បរិច្ឆេទទី ២

## ចេតសិកសង្គហៈ

រៀបរៀងដោយព្រះសទ្ធម្មជោតិកៈ

ប្រែដោយឧបាសក ហួយ គឹមឈុន

ពុទ្ធសករាជ ២៥៦០

| | |
|---|---|
| ឈ្មោះសៀវភៅ | បរមត្ថជោតិកៈ បរិច្ឆេទទី ២<br>ចេតសិកសង្គហៈ |
| រចនាដោយ | ព្រះសទ្ធម្មជោតិកៈ |
| ប្រែដោយ | ហួយ គឹមឈុន |
| ពិនិត្យដោយ | ហួយ វ៉ាន់ថន, វុិត ណារិន |
| វាយអក្សរដោយ | ហួយ វ៉ាន់ថន និង ស៊ិក គង់ |
| ការផ្សាយ | ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| សម្រាប់ជា | ធម្មទាន |
| ព.ស. | ២៥៦០ |

# បរមត្ថជោតិកៈ

## បរិច្ឆេទទី ២

## ចេតសិកសង្គហៈ

**មាតិកា** **ទំព័រ**


| | |
|---|---|
| លក្ខណៈ ៤ ប្រការរបស់ចេតសិក | ១ |
| ចែកចេតសិក ៥២ ដោយរាសី | ៣ |
| ចែករាសី ៣ ដោយប្រភេទ | ៤ |
| កម្រងទី ១ | ៥ |
| កម្រងទី ២ | ៦ |
| **អត្ថរបស់ចេតសិក ៥២** | |
| **អញ្ញសមានចេតសិក ១៣** | |
| សព្វចិត្តសាធារណចេតសិក ៧ | ៧ |
| បកិណ្ណកចេតសិក ៦ | ៨ |
| **អកុសលចេតសិក ១៤** | |
| មោចតុក្កចេតសិក ៤ | ៩ |
| លោភតិកចេតសិក ៣ | ១០ |
| ទោចតុក្កចេតសិក ៤ | ១០ |
| ថិទុកចេតសិក ២ | ១១ |
| វិចិកិច្ឆាចេតសិក ១ | ១១ |

## សោភណចេតសិក ២៥

សោភណសាធារណចេតសិក ១៩ ១១
វិរតិចេតសិក ៣ ១៤
អប្បមញ្ញាចេតសិក ២ ១៤
បញ្ញិន្ទ្រិយចេតសិក ១ ១៥

## សម្បយោគន័យ

អារម្ភបទនៃសម្បយោគន័យ ១៥
សម្បយោគន័យដោយសង្ខេប ១៥
សម្បយោគន័យអញ្ញសមានចេតសិក ១៣ ១៦
សង្គហគាថា ១៨
សម្បយោគន័យអកុសលចេតសិក ១៤ ១៩
សង្គហគាថាសម្តែងសម្បយោគន័យ ៥ ក្នុងអកុសលចេតសិក ១៤ ១៩
សម្បយោគន័យសោភណចេតសិក ២៥ ២០
គាថាសម្តែងសម្បយោគ ៤ ន័យក្នុងសោភណចេតសិក ២៥ ២១
អធិប្បាយវិសេសក្នុងការប្រកបរបស់អប្បមញ្ញាចេតសិក ២ ២២
អនិយតយោគី និងនិយតយោគីចេតសិក ២៣

## សង្គហន័យ

អកុសលសង្គហន័យ ៣០
គាថាសម្តែងសង្គហន័យ ៧ ន័យក្នុងអកុសលចិត្ត ១២ ៣១

គាថាសម្តែងសព្វាកុសលយោគីចេតសិក ១៤ ៣២
អហេតុកសង្គហន័យ ៣២
គាថាសម្តែងសង្គហន័យ ៤ ន័យក្នុងអហេតុកចិត្ត ១៨ ៣៣
កាមាវចរសោភណសង្គហន័យ ៣៤
មហគ្គតសង្គហន័យ ៣៧
គាថាសង្គហៈសម្តែងសង្គហន័យ ៥ ន័យក្នុងមហគ្គតចិត្ត ២៧ ៣៧
លោកុត្តរសង្គហន័យ ៣៨
គាថាសង្គហៈសម្តែងសង្គហន័យ ៥ ន័យក្នុងលោកុត្តរចិត្ត ៤០ ៣៨
គាថាសម្តែងសោភណចេតសិកដែលមិនប្រកបនឹងសោភណចិត្តពួកខ្លះ ៣៩
ហេតុផលដែលវិរតិចេតសិក ៣ មិនប្រកបក្នុងមហាវិបាក-
និងមហាកិរិយាចិត្ត ៤០
ហេតុផលដែលវិរតិចេតសិក ៣ មិនប្រកបនឹងមហគ្គតចិត្ត ៤០
ហេតុផលដែលអប្បមញ្ញាចេតសិកមិនប្រកបនឹងមហាវិបាកចិត្ត
និងលោកុត្តរចិត្ត ៤០
គាថាសម្តែងចេតសិកដែលធ្វើឲ្យចិត្តផ្សេងគ្នា ៤១

**ឥឡូវភយមិស្សកន័យគឺសម្បយោគន័យនិងសង្គហន័យរួមគ្នា**

អញ្ញសមានរាសី ៤២
អកុសលរាសី ៤៣

សោភណាភសី ៤៥
គាថាសម្ដែងចំនួនចេតសិកដោយពិស្ដារ ៣៤២៦ ដួង ៤៧

# បរមត្ថជោតិកៈ

## បរិច្ឆេទទី ២ ចេតសិកសង្គហៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*ក្នុងបរិច្ឆេទទី ១ ចិត្តសង្គហៈ បានពោលដល់ចិត្តបរមត្ថ ឥឡូវនេះនឹងបានពោលដល់សភាវៈរបស់ចេតសិកបរមត្ថតទៅ ។*

*តាមធម្មតា សត្វទាំងឡាយ សូម្បីមានអវយវៈគ្រប់គ្រាន់បរិបូណ៌ក៏ដោយ បើមិនមាននាមធម៌ គឺចិត្ត ចេតសិកហើយ សត្វទាំងឡាយនោះ ក៏មិនមានការដឹង និងមិនអាចធ្វើអ្វីផ្សេងៗ បាន មិនបានអ្វីផ្សេងៗពីរូបនោះឡើយ ក្នុងបណ្ដាចិត្ត ចេតសិកទាំង ២ នេះ ជាធម្មជាតកើតព្រមគ្នា និងរលត់ព្រមគ្នា ទទួលអារម្មណ៍ជាមួយគ្នា និងអាស្រ័យវត្ថុជាទីកើតជាមួយគ្នា និងបែកចេញពីគ្នាមិនបាន ឧបមាដូចគ្រឿងចក្រ ត្រូវប្រើខ្សែភ្លើង បើមានតែគ្រឿងចក្រ មិនអាចធ្វើការងារបាន និងគ្រឿងចក្រដែលកំពុងវិលធ្វើការងារនោះគឺអាស្រ័យភ្លើងនោះ ឯខ្សែភ្លើងនោះត្រូវប្រកបខ្សែ ២ រួមគ្នា ខ្សែទាំង ២ នោះ បើដាច់ខ្សែណាមួយហើយ គ្រឿងចក្រនោះក៏មិនអាចធ្វើការបានដូចគ្នា ដូច្នោះ ដើម្បីឲ្យបណ្ឌិតទាំងឡាយបានដឹងដល់ការប្រព្រឹត្តទៅនៃសភាវៈរបស់ចិត្ត ចេតសិកនោះ ព្រះអនុរុទ្ធាចារ្យបានសម្ដែងថា*

### លក្ខណៈ ៤ ប្រការរបស់ចេតសិក

ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា
ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា ធម្មា ។

អ្នកសិក្សាទាំងឡាយ គប្បីដឹងធម្មជាតរបស់ចេតសិក ដែលមានចំនួន ៥២ ដួង ដែលប្រកបជាមួយចិត្ត មានលក្ខណៈ ៤ គឺ កើតព្រមជាមួយចិត្ត ១ រលត់ព្រមជាមួយចិត្ត ១ មានអារម្មណ៍តែមួយជាមួយចិត្ត ១ មានទីអាស្រ័យតែមួយជាមួយចិត្ត ១ ។

## អធិប្បាយ

ព្រះអនុរុទ្ធាចារ្យសម្ដែងគាថាបទនេះ ដើម្បីពន្យល់ពាក្យថា ចេតសិកំ ពោលទុកក្នុងអារម្មណ៍បទខាងដើមរបស់អភិធម្មត្ថសង្គហបករណ៍នេះថា

"ចិត្តំ ចេតសិកំ រូបំ និព្វានមិតិ សព្វថា"

និងដើម្បីឲ្យអ្នកសិក្សាទាំងឡាយជ្រាបដល់លក្ខណៈ អាការៈ ដែលប្រកបនឹងចិត្តរបស់ចេតសិកទាំង ៥២ ដួង ហៅថា **ចេតោយុត្តលក្ខណៈ** ប្រកបដោយលក្ខណៈ ៤ ប្រការ គឺ

**១. ឯកុប្បាទៈ** ចេតសិកនេះកើតព្រមនឹងចិត្តជានិច្ច មានន័យថា កាលចិត្តកើតឡើង ចេតសិកក៏កើតឡើងព្រមគ្នា នឹងថាចិត្តកើតមុន ចេតសិកកើតក្រោយ ឬ ចេតសិកកើតមុន ចិត្តកើតក្រោយនោះមិនបាន ។

**២. ឯកនិរោធៈ** ក្នុងទំនងដូចគ្នានោះ កាលចិត្តរលត់ ចេតសិកក៏រលត់ផង មិនមានខាងណារលត់មុន ឬរលត់ក្រោយ ។

**៣. ឯកាលម្ពណៈ** អារម្មណ៍ដែលចេតសិកចូលទៅទទួលនោះ ក៏ជាអារម្មណ៍តែមួយជាមួយគ្នានឹងចិត្ត ដែលបានទទួលនោះឯង ដូចជាចិត្តទទួល

អារម្មណ៍ពណ៌ស ចេតសិកក៏ទទួលពណ៌ស ចិត្តទទួលអារម្មណ៍ពណ៌ខ្មៅ ចេតសិកក៏ទទួលពណ៌ខ្មៅ ដូចនេះជាដើម ។

៤. **ឯកវត្ថុក:** ទីអាស្រ័យរបស់ចេតសិក ក៏ជាប្រភេទតែមួយជាមួយគ្នានឹងទីអាស្រ័យរបស់ចិត្ត ដូចជាចិត្តអាស្រ័យភ្នែកកើតឡើង ចេតសិកក៏អាស្រ័យភ្នែកកើតឡើងដែរ ចិត្តអាស្រ័យត្រចៀកកើតឡើង ចេតសិកក៏អាស្រ័យត្រចៀកកើតឡើងផងដែរ ចិត្តអាស្រ័យបេះដូងកើតឡើង ចេតសិកក៏អាស្រ័យបេះដូងកើតឡើងដែរ ដូចនេះជាដើម ។

កាលបានគ្រប់លក្ខណ:ទាំង ៤ ប្រការដូចពោលមកហើយ ក៏បានឈ្មោះថា **ចេតសិក** ។

ក្នុងបណ្តាយុត្តលក្ខណ:ទាំង ៤ ប្រការនោះ **ឯកុប្បាទ: ឯកនិរោធ: ឯកាលម្ពណ:** ទាំង ៣ ប្រការនេះមាននៅក្នុងចេតសិកដោយពិតប្រាកដ ចំណែកលក្ខណ:ទី ៤ គឺ **ឯកវត្ថុក:** នោះមិនមែនជាលក្ខណ:ដែលមានដោយពិតប្រាកដ ព្រោះថាចេតសិកទាំងនេះ កាលកើតក្នុងបញ្ចវោការភូមិ ទើបត្រូវអាស្រ័យវត្ថុកើតឡើង តែបើកើតក្នុងចតុវោការភូមិ ក៏មិនចាំបាច់ត្រូវអាស្រ័យវត្ថុ ។

## ចែកចេតសិក ៥២ ដោយរាសី

ចេតសិក ៥២ ដួងនេះ ចែកចេញជា ៣ ពួក ហៅថា **រាសី** គឺ អញ្ញសមានរាសីចេតសិក ១ ពួកមានចំនួន ១៣ ដួង, អកុសលរាសីចេតសិក ១ ពួកមានចំនួន ១៤ ដួង, សោភណរាសីចេតសិក ១ ពួកមានចំនួន ២៥ ដួង ឬហៅថា

អញ្ញសមានចេតសិក ១៣ អកុសលចេតសិក ១៤ សោភណចេតសិក ២៥ ក៏បាន ។

## ចែករាសី ៣ ដោយប្រភេទ

ចេតសិកដែលជាអញ្ញសមានរាសីនោះ ចែកជា ២ ប្រភេទ គឺ

១. សព្វចិត្តសាធារណចេតសិក ៧ ដួងមួយប្រភេទ

២. បកិណ្ណកចេតសិក ៦ ដួងមួយប្រភេទ ។

ចេតសិកដែលជាអកុសលរាសីនោះ ចែកជា ៥ ប្រភេទ គឺ

១. មោចតុក្កចេតសិក ៤ ដួង មួយប្រភេទ

២. លោតិកចេតសិក ៣ ដួង មួយប្រភេទ

៣. ទោចតុក្កចេតសិក ៤ ដួង មួយប្រភេទ

៤. ថិទុកចេតសិក ២ ដួង មួយប្រភេទ

៥. វិចិកិច្ឆាចេតសិក ១ ដួង មួយប្រភេទ ។

ចេតសិកដែលជាសោភណរាសីនោះ ចែកជា ៤ ប្រភេទ គឺ

១. សោភណសាធារណចេតសិក ១៩ ដួង មួយប្រភេទ

២. វិរតិចេតសិក ៣ ដួង មួយប្រភេទ

៣. អប្បមញ្ញាចេតសិក ២ ដួង មួយប្រភេទ

៤. បញ្ញិន្ទ្រិយចេតសិក ១ ដួង មួយប្រភេទ ។

## កម្រងទី ១

តេរសញ្ញសមានា ច    ចុទ្ទសាកុសលា តថា
សោភណា បញ្ចវីសាតិ    ទ្វិបញ្ញាស បវុច្ចរេ ។

- ចេតសិក ៥២
  - អញ្ញសមានចេតសិក ១៣
  - អកុសលចេតសិក ១៤
  - សោភណចេតសិក ២៥

- អញ្ញសមានចេតសិក ១៣
  - សព្វចិត្តសាធារណចេតសិក ៧
  - បកិណ្ណកចេតសិក ៦

- អកុសលចេតសិក ១៤
  - មោចតុក្កចេតសិក ៤
  - លោតិកចេតសិក ៣
  - ទោចតុក្កចេតសិក ៤
  - ថិទុកចេតសិក ២
  - វិចិកិច្ឆាចេតសិក ១

- សោភណចេតសិក ២៥
  - សោភណសាធារណចេតសិក ១៩
  - វិរតិចេតសិក ៣
  - អប្បមញ្ញាចេតសិក ២
  - បញ្ញិន្ទ្រិយចេតសិក ១

## ចេតសិក ៥២

*សព្វចិត្តសាធារណចេតសិក ៧*
*បកិណ្ណកចេតសិក ៦*
} *អញ្ញសមានចេតសិក ១៣*

*មោចតុក្កចេតសិក ៤*
*លោតិកចេតសិក ៣*
*ទោចតុក្កចេតសិក ៤*
*ថិទុកចេតសិក ២*
*វិចិកិច្ឆាចេតសិក ១*
} *អកុសលចេតសិក ១៤*

*សោភណសាធារណចេតសិក ១៩*
*វិរតិចេតសិក ៣*
*អប្បមញ្ញាចេតសិក ២*
*បញ្ញិន្ទ្រិយចេតសិក ១*
} *សោភណចេតសិក ២៥*

*អញ្ញសមានចេតសិក ១៣*, *អកុសលចេតសិក ១៤*, *សោភណចេតសិក ២៥* } *ចេតសិក ៥២*

## ក្រុមទី ២

***សព្វចិត្តសាធារណចេតសិក ៧*** *គឺ ផស្សៈ, វេទនា, សញ្ញា, ចេតនា, ឯកគ្គតា, ជីវិតិន្ទ្រិយ, មនសិការៈ ។*

***បកិណ្ណកចេតសិក ៦*** *គឺ វិតក្កៈ, វិចារៈ, អធិមោក្ខៈ, វីរិយៈ បីតិ, ឆន្ទៈ ។*

***មោចតុក្កចេតសិក ៤*** *គឺ មោហៈ, អហិរិកៈ, អនោត្តប្បៈ, ឧទ្ធច្ចៈ ។*

***លោតិកចេតសិក ៣*** *គឺ លោភៈ, ទិដ្ឋិ, មានះ ។*

***ទោចតុក្កចេតសិក ៤*** *គឺ ទោសៈ, ឥស្សា, មច្ឆរិយៈ, កុក្កុច្ចៈ ។*

***ថិទុកចេតសិក ២*** *គឺ ថិនៈ, មិទ្ធៈ ។*

***វិចិកិច្ឆាចេតសិក ១*** *គឺ វិចិកិច្ឆា ។*

***សោភណសាធារណចេតសិក ១៩*** *គឺ សទ្ធា, សតិ, ហិរិ, ឱត្តប្បៈ, អលោភៈ, អទោសៈ, តត្រមជ្ឈត្តតា, កាយបស្សទ្ធិ, ចិត្តបស្សទ្ធិ, កាយលហុតា, ចិត្តលហុតា, កាយមុទុតា, ចិត្តមុទុតា, កាយកម្មញ្ញតា, ចិត្តកម្មញ្ញតា, កាយបាគុញ្ញតា, ចិត្តបាគុញ្ញតា, កាយុជុកតា, ចិត្តុជុកតា ។*

***វិរតិចេតសិក ៣*** *គឺ សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ ។*

***អប្បមញ្ញាចេតសិក ២*** *គឺ ករុណា, មុទិតា ។*

***បញ្ញិន្ទ្រិយចេតសិក ១*** *គឺ បញ្ញា ។*

## អត្ថរបស់ចេតសិក ៥២

## អញ្ញសមានចេតសិក ១៣

## សព្វចិត្តសាធារណចេតសិក ៧

១. ផស្សោ ធម្មជាតដែលប៉ះផ្ទប់អារម្មណ៍ ។

២. វេទនា ធម្មជាតិដែលសោយអារម្មណ៍ ។

៣. សញ្ញា ធម្មជាតិដែលចាំអារម្មណ៍ ។

៤. ចេតនា ធម្មជាតិដែលជំរុញ និងឲ្យសម្បយុត្តធម៌តាំងនៅក្នុងអារម្មណ៍ដើម្បីឲ្យធ្វើមុខនាទីរបស់ខ្លួន ។

៥. ឯកគ្គតា ធម្មជាតិដែលស្ងប់ និងឲ្យសម្បយុត្តធម៌តាំងក្នុងនៅអារម្មណ៍តែមួយ ។

៦. ជីវិតិន្ទ្រិយំ ធម្មជាតដែលរក្សាសម្បយុត្តធម៌ ។

៧. មនសិការោ ធម្មជាតដែលតាំងចិត្ត និងនាំសម្បយុត្តធម៌ទៅកាន់អារម្មណ៍ ។

ចេតសិក ៧ ដូងនេះ ឈ្មោះថា **សព្វចិត្តសាធារណៈ** ព្រោះប្រកបជាមួយនឹងចិត្តទូទៅទាំងអស់ ។ កាលញែកបទហើយបាន ៣ បទ គឺ សព្វ + ចិត្ត + សាធារណ ។ សព្វ = ទាំងអស់, ចិត្ត = ចិត្ត, សាធារណ = ទូទៅ មិនចំពោះ, ដូច្នេះរួមទាំង ៣ បទ បានជា **សព្វចិត្តសាធារណៈ** = ទូទៅដល់ចិត្តទាំងអស់ ។

## បកិណ្ណកចេតសិក ៦

១. វិតក្កោ ធម្មជាតដែលលើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ គឺគិតត្រិះរិះអារម្មណ៍ ។

២. វិចារោ ធម្មជាតដែលពិចារណាអារម្មណ៍ ។

៣. អធិមោក្ខោ ធម្មជាតចុះស៊ប់ក្នុងអារម្មណ៍ ។

៤. វីរិយំ ធម្មជាតដែលមានការព្យាយាមក្នុងអារម្មណ៍ ។

៥. បីតិ ធម្មជាតិដែលឆ្អែតក្នុងអារម្មណ៍ ។

៦. ឆន្ទោ ធម្មជាតពេញចិត្តអារម្មណ៍ ។

ចេតសិក ៦ ដូងនេះឈ្មោះថា **បកិណ្ណកចេតសិក** ព្រោះប្រកបក្នុងចិត្តទូទៅ (គឺអកុសលចិត្ត កុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត) តែបានចំនួនខ្លះ មិនទាំងអស់គ្រប់ដួងទេ ។ កាលញែកបទហើយបាន ៣ គឺ ប + កិណ្ណ + ក ។ ប = ដោយទូទៅ,

កិណ្ណ = រាយរង, ក = មិនមានសេចក្តីដោយចំពោះ រួមទាំង ៣ បទជា បកិណ្ណក = រាយរងដោយទូទៅ មានន័យថា ចេតសិក ៦ ដួងនេះប្រកបទូទៅ ទាំងជាលោកិយៈ លោកុត្តរៈ សោភណៈ អសោភណៈ កុសល អកុសល វិបាក កិរិយា តែមិនទាំងអស់ទេ ផ្សេងពីការប្រកបរបស់សព្វចិត្តសាធារណចេតសិក ដែលប្រកបបានទូទៅ និងបានទាំងអស់គ្រប់ៗ ដួង ។

សព្វចិត្តសាធារណចេតសិក ៧ បកិណ្ណកចេតសិក ៦ រួមជា ១៣ ដួងនេះឈ្មោះថា អញ្ញសមានចេតសិក ព្រោះចេតសិកទាំងនេះមានសភាពដូចធម៌ដទៃពោលគឺ សោភណចេតសិកមានសទ្ធាជាដើមក្តី អសោភណចេតសិកមានមោហៈជាដើមក្តី រមែងជាធម៌ដទៃពីអញ្ញសមានចេតសិក តែអញ្ញសមាន-ចេតសិក ក៏ដូចនឹងចេតសិកទាំង ២ ពួកនេះ ទើបប្រកបនឹងចិត្តរួមគ្នាបានផ្សេងពីអសោភណចេតសិក ដែលមិនអាចប្រកបនឹងសោភណចេតសិក ឬសោភណចេតសិកមិនអាចប្រកបនឹងអសោភណចេតសិក ។

## អកុសលចេតសិក ១៤

## មោចតុក្កចេតសិក ៤

១. មោហោ ធម្មជាតដែលបិទបាំងសភាវៈពិតក្នុងអារម្មណ៍ ។

២. អហិរិកំ ធម្មជាតដែលមិនខ្មាសអំពើទុច្ចរិត ។

៣. អនោត្តប្បំ ធម្មជាតដែលមិនខ្លាចអំពើទុច្ចរិត ។

៤. ឧទ្ធច្ចំ ធម្មជាតរាយមាយ គឺទទួលអារម្មណ៍មិនមាំទាំ ។

ចេតសិកទាំង ៤ នេះឈ្មោះថា **មោចតុក្កៈ** ព្រោះលើកមោហចេតសិកជាប្រធាន និងចេតសិក ៤ ដូចនេះឯង ឈ្មោះថា **សព្វាកុសលសាធារណចេតសិក** ផង ព្រោះចេតសិកពួកនេះប្រកបនឹងអកុសលចិត្តទាំង ១២ ដោយទូទៅទាំងអស់ ។

## លោតិកចេតសិក ៣

១. លោភោ ធម្មជាតដែលមានសេចក្ដីត្រូវការ ជាប់ចិត្តក្នុងអារម្មណ៍ជាកាមគុណ ។

២. ទិដ្ឋិ ធម្មជាតិដែលមានសេចក្ដីយល់ខុសក្នុងអារម្មណ៍ ។

៣. មានោ ធម្មជាតដែលមានសេចក្ដីឆ្មើងកន្ទ្រើង ក្រអឺតក្រទម ប្រកាន់ខ្លួន ។

ចេតសិក ៣ ដូចនេះ ឈ្មោះថា **លោតិកៈ** ព្រោះ មានលោភចេតសិកជាប្រធាន ។

## ទោចតុក្កចេតសិក ៤

១. ទោសោ ធម្មជាតដែលប្រទុស្តក្នុងអារម្មណ៍ ។

២. ឥស្សា ធម្មជាតិដែលមានសេចក្ដីមិនពេញចិត្តនឹងទ្រព្យសម្បត្តិ ឬសេចក្ដីល្អរបស់អ្នកដទៃ គឺសេចក្ដីច្រណែន ។

៣. មច្ឆរិយំ ធម្មជាតដែលមានការហួងហែងទ្រព្យសម្បត្តិ និងសេចក្ដីល្អមិនដល់ខ្លួន គឺសេចក្ដីកំណាញ់ ។

៤. កុក្កុច្ចំ ធម្មជាតដែលមានសេចក្ដីក្ដៅក្រហាយក្នុងទុច្ចរិតដែលខ្លួនបានធ្វើ និងក្នុងសុចរិតដែលមិនបានធ្វើ ។

ចេតសិក ៤ ដូចនេះ ឈ្មោះថា **ទោចតុក្កៈ** ព្រោះលើកទោសចេតសិកជាប្រធាន ។

## ថិទុកចេតសិក ២

១. ថីនំ ធម្មជាតដែលធ្វើឲ្យចិត្តរួញរា រាថយចាកអារម្មណ៍ ។

២. មិទ្ធំ ធម្មជាតដែលធ្វើឲ្យចិត្តរាយមាយ សេចក្ដីងោងក់ ។

## វិចិកិច្ឆាចេតសិក ១

វិចិកិច្ឆា ធម្មជាតិដែលមានសេចក្ដីសង្ស័យ ស្ទាក់ស្ទើរ ។

ចេតសិក ១៤ ដូចនេះ ឈ្មោះថា អកុសលចេតសិក ព្រោះប្រកបនឹងអកុសលចិត្តតែម្យ៉ាង ។

## សោភណចេតសិក ២៥

## សោភណសាធារណចេតសិក ១៩

១. សទ្ធា ធម្មជាតិដែលមានសេចក្ដីជឿ និងជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងជឿលើកម្ម និងផលរបស់កម្មជាដើម ។

២. សតិ ធម្មជាតិដែលមានសេចក្ដីរឭកក្នុងអារម្មណ៍ ដែលទាក់ទងនឹងកុលសកម្ម មានគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើម ។

៣. ហិរិ ធម្មជាតិដែលមានសេចក្ដីស្អប់ និងខ្មាស់ចំពោះអំពើទុច្ចរិត ។

៤. ឱត្តប្បំ ធម្មជាតដែលមានសេចក្ដីខ្លាចអំពើទុច្ចរិត ។

៥. អលោភោ ធម្មជាតដែលមិនប្រាថ្នា និងមិនជាប់ជំពាក់ក្នុងអារម្មណ៍ជាកាមគុណ ។

៦. អទោសោ ធម្មជាតដែលមិនប្រទុស្តក្នុងអារម្មណ៍ ។

៧. តត្រមជ្ឈត្តតា ធម្មជាតិដែលធ្វើឲ្យចិត្ត និងចេតសិកប្រព្រឹត្តទៅស្មើក្នុងកិច្ចរបស់ខ្លួនៗ មិនឲ្យមានការលើស ឬខ្វះ ។

៨. កាយបស្សទ្ធិ ធម្មជាតិដែលជាសេចក្ដីស្ងប់នៃចេតសិកខន្ធ ៣ (គឺវេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ) ក្នុងការងារដែលជាកុសល ។

៩. ចិត្តបស្សទ្ធិ ធម្មជាតិដែលជាសេចក្ដីស្ងប់នៃចិត្ត ក្នុងការងារដែលជាកុសល ។

១០. កាយលហុតា ធម្មជាតិដែលជាសេចក្ដីស្រាលនៃចេតសិកខន្ធ ៣ ក្នុងការងារដែលជាកុសល ។

១១. ចិត្តលហុតា ធម្មជាតិដែលជាសេចក្ដីស្រាលនៃចិត្ត ក្នុងការងារដែលជាកុសល ។

១២. កាយមុទុតា ធម្មជាតិដែលជាសេចក្ដីទន់ភ្លន់នៃចេតសិកខន្ធ ៣ ក្នុងការងារដែលជាកុសល ។

១៣. ចិត្តមុទុតា ធម្មជាតិដែលជាសេចក្ដីទន់ភ្លន់នៃចិត្ត ក្នុងការងារដែលជាកុសល ។

១៤. កាយកម្មញ្ញតា ធម្មជាតិដែលជាសេចក្ដីគួរដល់ការងារនៃចេតសិកខន្ធ ៣ ក្នុងការងារដែលជាកុសល ។

១៥. ចិត្តកម្មញ្ញតា ធម្មជាតិដែលជាសេចក្ដីគួរដល់ការងារនៃចិត្ត ក្នុងការងារដែលជាកុសល ។

១៦. កាយបាគុញ្ញតា ធម្មជាតិដែលជាសេចក្ដីស្ទាត់ជំនាញនៃចេតសិកខន្ធ ៣ ក្នុងការងារដែលជាកុសល ។

១៧. ចិត្តបាគុញ្ញតា ធម្មជាតិដែលជាសេចក្ដីស្ទាត់ជំនាញនៃចិត្ត ក្នុងការងារដែលជាកុសល ។

១៨. កាយុជុកតា ធម្មជាតិដែលជាសេចក្ដីត្រង់នៃចេតសិកខន្ធ ៣ ក្នុងការងារដែលជាកុសល ។

១៩. ចិត្តុជុកតា ធម្មជាតិដែលជាសេចក្ដីត្រង់នៃចិត្ត ក្នុងការងារដែលជាកុសល ។

ក្នុងបណ្ដាសោភណសាធារណចេតសិកនោះ បស្សទ្ធិចេតសិក, លហុតាចេតសិក, មុទុតាចេតសិក, កម្មញ្ញតាចេតសិក, បាគុញ្ញតាចេតសិក ឧជុកតាចេតសិក ទាំង ៦ ដួងនេះជាគូគ្នា ទើបរួមជា ១២ ដួង រាប់ទាំងសទ្ធាចេតសិកជាដើម សោភណសាធារណចេតសិកទើបមាន ១៩ ដួង ចេតសិកទាំងនេះ

ឈ្មោះថា សោភណសាធារណ:នោះ ព្រោះប្រកបក្នុងសោភណចិត្តទូទៅទាំងអស់ ។ កាលញែកបទហើយមាន ២ គឺ សោភណ + សាធារណ ។ សោភណ = ចិត្តដែលល្អស្អាតមិនមានទោស, សាធារណ = ទូទៅ កាលរួមទាំង ២ បទជា សោភណសាធារណ = ទូទៅក្នុងចិត្តដែលមានសេចក្ដីស្អាតមិនមានទោស ។

## វិរតិចេតសិក ៣

១. សម្មាវាចា ការពោលវាចាប្រពៃ ដោយវៀរចាកវចីទុច្ចរិត ៤ ដែលមិនជាប់ទាក់ទងនឹងការងារចិញ្ចឹមជីវិត ។

២. សម្មាកម្មន្តោ ការងារប្រពៃ ដោយវៀរចាកកាយទុច្ចរិត ៣ ដែលមិនជាប់ទាក់ទងនឹងការងារចិញ្ចឹមជីវិត ។

៣. សម្មាអាជីវោ ការចិញ្ចឹមជីវិតប្រពៃ ដោយវៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលជាប់ទាក់ទងនឹងការងារចិញ្ចឹមជីវិត ។

ចេតសិក ៣ ដូចនេះឈ្មោះថា **វិរតិចេតសិក** ព្រោះមានចេតនាវៀរចាកទុច្ចរិតជាប្រធាន ។

## អប្បមញ្ញាចេតសិក ២

១. ករុណា ធម្មជាតិដែលមានសេចក្ដីអាណិតចំពោះទុក្ខិតសត្វ គឺអ្នកដែលកំពុងទទួលសេចក្ដីទុក្ខលំបាក ឬនឹងបានទទួលសេចក្ដីទុក្ខលំបាកក្នុងកាលខាងមុខ ។

២. មុទិតា ធម្មជាតិដែលមានសេចក្ដីត្រេកអរចំពោះសុខិតសត្វ គឺអ្នកកំពុងទទួលសេចក្ដីសុខ ឬនឹងបានទទួលសេចក្ដីសុខក្នុងកាលខាងមុខ ។

ចេតសិក ២ ដូងនេះឈ្មោះថា អប្បមញ្ញាចេតសិក ព្រោះកើតឡើងដោយអាស្រ័យទុក្ខិតសត្វ និង សុខិតសត្វទូទៅ មិនមានកំណត់ ។

## បញ្ញិន្ទ្រិយចេតសិក ១

បញ្ញា ធម្មជាតិដែលដឹងនូវសភាវធម៌ទូទៅ តាមសេចក្ដីពិត ។

ចេតសិកដូងនេះឈ្មោះថា **បញ្ញិន្ទ្រិយ** ព្រោះមាននាទីគ្រប់គ្រងដឹងផ្សេងៗដោយទូទៅតាមសេចក្ដីពិត ។

## សម្បយោគន័យ

## អារម្ភបទនៃសម្បយោគន័យ

តេសំ ចិត្តាវិប្បយុត្តានំ    យថាយោគមិតោ បរំ

ចិត្តុប្បាទេសុ បច្ចេកំ    សម្បយោគោ បវុច្ចតិ ។

តទៅនេះ នឹងសម្ដែងការប្រកបដោយចំពោះៗ របស់ចេតសិកដែលមានសភាពកើតព្រមនឹងចិត្ត កាលចិត្តកើតឡើងតាមដែលនឹងប្រកបបាន ។

## សម្បយោគន័យដោយសង្ខេប

សត្ត សព្វត្ថ យុជ្ជន្តិ    យថាយោគំ បកិណ្ណកា

ចុទ្ទសាកុសលេស្វេវ    សោភណេស្វេវ សោភណា ។

សព្វចិត្តសាធារណចេតសិក ៧ រមែងប្រកបទូទៅក្នុងចិត្តទាំងអស់ បកិណ្ណកចេតសិក ៦ រមែងប្រកបក្នុងចិត្តដែលអាចប្រកបបាន អកុសលចេតសិក

១៤ រមែងប្រកបក្នុងអកុសលចិត្ត ១២ ប៉ុណ្ណោះ សោភណចេតសិក ២៥ រមែងប្រកបក្នុងសោភណចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ ។

## **អធិប្បាយ**

គាថានេះ សម្តែងគោលរបស់សម្បយោគន័យដោយសង្ខេប ដើម្បីឲ្យអ្នកសិក្សាទាំងឡាយ កាន់យកជាគោលសិន ទើបសម្តែងសេចក្តីពន្យល់ក្នុងសម្បយោគន័យដោយពិស្តារតទៅ

## **សម្បយោគន័យអញ្ញសមានចេតសិក ១៣**

អញ្ញសមានចេតសិក ១៣ នេះ មានសម្បយោគ ៧ ន័យ គឺ

សព្វចិត្តសាធារណចេតសិក ៧ ដួង រាប់ជាសម្បយោគន័យ ១ ន័យ ។

បកិណ្ណកចេតសិក ៦ ដួង រាប់ជាសម្បយោគន័យ ៦ ន័យ ។

***សព្វចិត្តសាធារណចេតសិក ៧*** ដួងប្រកបក្នុងចិត្តទាំងអស់ ៨៩ ឬ ១២១ ដួង ។

***វិតក្កចេតសិក*** ប្រកបបានក្នុងចិត្ត ៥៥ ដួង គឺ កាមចិត្ត ៤៤ (វៀរទ្វិបញ្ច-វិញ្ញាណចិត្ត ១០) និងបឋមជ្ឈានចិត្ត ១១ ដួង រួមជា ៥៥ ។ មិនប្រកបជាមួយចិត្ត ៦៦ ដួង គឺទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ រួមជា ៦៦ ។

***វិចារចេតសិក*** ប្រកបបានក្នុងចិត្ត ៦៦ គឺ កាមចិត្ត ៤៤ (វៀទ្វិបញ្ចវិញ្ញាណ-ចិត្ត ១០) និងបឋមជ្ឈាចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ រួមជា ៦៦ ។ ប្រកបមិនបាន

ក្នុងចិត្ត ៥៥ ដួង គឺទ្វិបញ្ចវិញ្ញាណចិត្ត ១០ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ រួមជា ៥៥ ដួង ។

**អធិមោក្ខចេតសិក** ប្រកបបានក្នុងចិត្ត ១១០ ដួងគឺ កាមចិត្ត ៤៣ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ វិចិកិច្ឆាសម្បយុត្តចិត្ត ១) មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៤០ រួមជា ១១០ ។ ប្រកបមិនបានក្នុងចិត្ត ១១ គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ។

**វីរិយចេតសិក** ប្រកបបានក្នុងចិត្ត ១០៥ ដួងគឺ កាមចិត្ត ៣៨ (វៀរអហេតុកវិបាក ១៥ បញ្ចទ្វារាវជ្ជនចិត្ត ១) មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៤០ រួមជា ១០៥ ។ ប្រកបមិនបានក្នុងចិត្ត ១៦ ដួង គឺអហេតុកវិបាកចិត្ត ១៥ បញ្ចទ្វារាវជ្ជនចិត្ត ១ រួមជា ១៦ ។

**បីតិចេតសិក** ប្រកបបានក្នុងចិត្ត ៥១ ដួង គឺកាមសោមនស្សសហគតចិត្ត ១៨ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ រួមជា ៥១ ។ ប្រកបមិនបានក្នុងចិត្ត ៧០ ដួង គឺ ទោសមូលចិត្ត ២ កាយវិញ្ញាណចិត្ត ២ ឧបេក្ខាសហគតចិត្ត ៥៥ ចតុត្ថជ្ឈានចិត្ត ១១ រួមជា ៧០ ដួង ។

**ឆន្ទចេតសិក** ប្រកបបានក្នុងចិត្ត ១០១ គឺ កាមចិត្ត ៣៤ (វៀរមោហមូលចិត្ត ២ អហេតុកចិត្ត ១៨) មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៤០ រួមជា ១០១ ។ ប្រកបមិនបានក្នុងចិត្ត ២០ ដួងគឺ មោហមូលចិត្ត ២ អហេតុកចិត្ត ១៨ រួមជា ២០ ។

## សង្គហគាថា

តេ បន ចិត្តុប្បាទា យថាក្កមំ–

ឆសដ្ឋិ បញ្ចបញ្ញាស ឯកាទស ច សោឡស
សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា ។

បញ្ចបញ្ញាស ឆសដ្ឋិ- ដ្ឋសត្តតិ តិសត្តតិ
ឯកបញ្ញាស ចេកូន- សត្តតិ សបកិណ្ណកា ។

*សរុបសេចក្តីថា ចិត្តទាំងឡាយដែលបកិណ្ណកចេតសិកទាំង ៦ ប្រកបមិនបាននោះមានចំនួនតាមលំដាប់នៃចេតសិកដូចតទៅនេះ គឺ ៦៦, ៥៥, ១១, ១៦, ៧០, ២០ ។ ចិត្តទាំងឡាយដែលបកិណ្ណកចេតសិកទាំង ៦ ប្រកបបាននោះមានចំនួនតាមលំដាប់នៃចេតសិក ដូចតទៅនេះ គឺ ៥៥, ៦៦, ៧៨ (ឬ ១១០), ៧៣ (ឬ ១០៥), ៥១, ៦៩ (ឬ ១០១) ។*

*សម្តែងចិត្តដែលបកិណ្ណកចេតសិកប្រកបបាន និងមិនបានតាមសង្គហគាថា*

| **បកិណ្ណកចេតសិក** | **ប្រកបបាន** | | **ប្រកបមិនបាន** | |
|---|---|---|---|---|
| *វិតក្កចេតសិក* | *បញ្ចបញ្ញាស* | *៥៥* | *ឆសដ្ឋិ* | *៦៦* |
| *វិចារចេតសិក* | *ឆសដ្ឋិ* | *៦៦* | *បញ្ចបញ្ញាស* | *៥៥* |
| *អធិមោក្ខចេតសិក* | *អដ្ឋសត្តតិ* | *៧៨ (១១០)* | *ឯកាទស* | *១១* |
| *វីរិយចេតសិក* | *តិសត្តតិ* | *៧៣ (១០៥)* | *សោឡស* | *១៦* |
| *បីតិចេតសិក* | *ឯកបញ្ញាស* | *៥១* | *សត្តតិ* | *៧០* |
| *ឆន្ទចេតសិក* | *ឯកូនសត្តតិ* | *៦៩ (១០១)* | *វីសតិ* | *២០* |

គាថាសង្គហៈដែលសម្តែងចំនួនចិត្តដែលប្រកបនឹងបកិណ្ណកចេតសិកនោះ មាន ២ ន័យ គឺ រាប់ចំនួនចិត្តដោយសង្ខេបខ្លះ ដោយពិស្តារខ្លះ ពោលគឺ បើចេតសិកដួងណាប្រកបនឹងលោកុត្តរចិត្តបានទាំងអស់ ចិត្តដែលប្រកបនឹងចេតសិកដួងនោះក៏រាប់យ៉ាងសង្ខេប គឺចិត្តដែលប្រកបនឹងអធិមោក្ខៈ វីរិយៈ ឆន្ទៈ បើចេតសិកដួងណាប្រកបនឹងលោកុត្តរចិត្តមិនបានទាំងអស់ ចិត្តដែលប្រកបនឹងចេតសិកដួងនោះក៏រាប់យ៉ាងពិស្តារ គឺចិត្តដែលប្រកបនឹងវិតក្កៈ វិចារៈ បីតិ ។

## សម្បយោគន័យអកុសលចេតសិក ១៤

***មោចតុក្កចេតសិក ៤*** *ប្រកបក្នុងអកុសលចិត្ត ១២ ទាំងអស់ ។*

***លោភចេតសិក*** *ប្រកបក្នុងលោភមូលចិត្ត ៨ ។*

***ទិដ្ឋិចេតសិក*** *ប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។*

***មានចេតសិក*** *ប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។*

***ទោចតុក្កចេតសិក ៤*** *ប្រកបបានក្នុងទោសមូលចិត្ត ២ ។*

***ថិទុកចេតសិក*** *ប្រកបក្នុងអកុសលសសង្ខារិកចិត្ត ៥ ។*

***វិចិកិច្ឆាចេតសិក*** *ប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ។*

## សង្គហគាថាសម្តែងសម្បយោគន័យ ៥ ក្នុងអកុសលចេតសិក ១៤

សព្វាបុញ្ញេសុ ចត្តារោ លោភមូលេ តយោ គតា
ទោសមូលេសុ ចត្តារោ សសង្ខារេ ទ្វយំ តថា ។

វិចិកិច្ឆា វិចិកិច្ឆា- ចិត្តេ ចាតិ ចតុទ្ទស
ទ្វាទសាកុសលេស្វេវ សម្បយុជ្ជន្តិ បញ្ចធា ។

អកុសលចេតសិក ១៤ រមែងប្រកបក្នុងអកុសលចិត្ត ១២ ប៉ុណ្ណោះ ដោយបែងចែកជា ៥ ន័យ គឺ

- មោចតុក្កចេតសិក ៤ ដែលប្រកបក្នុងអកុសលចិត្ត ១២ ទាំងអស់ រាប់ជា ១ ន័យ ។

- លោភ: ទិដ្ឋិ មានះ ៣ ដួង ដែលប្រកបក្នុងលោភមូលចិត្ត ៨ ដួងប៉ុណ្ណោះ រាប់ជា ១ ន័យ ។

- ទោចតុក្កចេតសិក ៤ ដែលប្រកបក្នុងទោសមូលចិត្ត ២ ដួងប៉ុណ្ណោះ រាប់ជា ១ ន័យ ។

- ថិទុកចេតសិក ២ ដែលប្រកបក្នុងអកុសលសសង្ខារិកចិត្ត ៥ ដួងប៉ុណ្ណោះ រាប់ជា ១ ន័យ ។

- វិចិកិច្ឆាចេតសិក ដែលប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួងប៉ុណ្ណោះ រាប់ជា ១ ន័យ ។

## សម្បយោគន័យសោភណចេតសិក ២៥

សោភណសាធារណចេតសិក ១៩ ប្រកបបានក្នុងសោភណចិត្ត ៥៩ ឬ ៩១ ។

វិរតិចេតសិក ៣ ប្រកបបានក្នុងចិត្ត ១៦ ដួងឬ ៤៨ ដួង គឺមហាកុសលចិត្ត ៨ ដួងលោកុត្តរចិត្ត ៨ ឬ ៤០ ។

អប្បមញ្ញាចេតសិក ២ ប្រកបបានក្នុងចិត្ត ២៨ គឺមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១២ (វៀរបញ្ចមជ្ឈានចិត្ត ៣) ។

បញ្ញាចេតសិកប្រកបក្នុងចិត្ត ៤៧ ដូចឬ ៧៩ គឺមហាកុសលញាណ-សម្បយុត្តចិត្ត ៤ មហាវិបាកញាណសម្បយុត្ត ៤ មហាកិរិយាញាណសម្បយុត្ត-ចិត្ត ៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ឬ ៤០ ។

**គាថាសម្ដែងសម្បយោគ ៤ ន័យក្នុងសោភណចេតសិក ២៥**

ឯកូនវីសតិ ធម្មា ជាយន្តេកូនសដ្ឋិសុ
តយោ សោឡសចិត្តេសុ អដ្ឋវីសតិយំ ទ្វយំ ។

បញ្ញា បកាសិតា សត្តចត្តាលីសវិធេសុបិ
សម្បយុត្តា ចតុធេវំ សោភណេស្វេវ សោភណា ។

សោភណចេតសិក ២៥ រមែងប្រកបក្នុងសោភណចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ ដោយបែងចែកជា ៤ ន័យ គឺ

- សោភណសាធារណចេតសិក ១៩ ដែលប្រកបក្នុងសោភណចិត្ត ៥៩ ឬ ៩១ រាប់ជា ១ ន័យ ។

- វិរតិចេតសិក ៣ ដែលប្រកបក្នុងចិត្ត ១៦ ឬ ៤៨ រាប់ជា ១ន័យ ។

- អប្បមញ្ញាចេតសិក ២ ដែលប្រកបក្នុងចិត្ត ២៨ រាប់ជា ១ ន័យ ។

- បញ្ញាចេតសិក ដែលប្រកបក្នុងចិត្ត ៤៧ ឬ ៧៩ រាប់ជា ១ ន័យ ។

**ចំណាំ** ពាក្យថា **សម្បយោគន័យនេះ** មានន័យថា ការលើកចេតសិកឡើងជាប្រធានហើយរកចំនួនចិត្តដែលចេតសិកនោះអាចប្រកបបាន ។

## សរុបសម្បយោគន័យ ១៦ ន័យ

- អញ្ញសមានចេតសិក ១៣ មានសម្បយោគន័យ ៧ ន័យ
- អកុសលចេតសិក ១៤ មានសម្បយោគន័យ ៥ ន័យ
- សោភណចេតសិក ២៥ មានសម្បយោគន័យ ៤ ន័យ

រួមជា សម្បយោគន័យ ១៦ ន័យ ។

## អធិប្បាយវិសេសក្នុងការប្រកបរបស់អប្បមញ្ញាចេតសិក ២

ការប្រកបរបស់អប្បមញ្ញាចេតសិក ២ នោះ មានវាទ:ជា ២ ន័យ គឺ សមានវាទ: បានដល់ វាទ:របស់អដ្ឋកថាចារ្យទាំងឡាយ មានព្រះអនុរុទ្ធាចារ្យជាដើម ពោលគឺ អប្បមញ្ញាចេតសិក ២ ដួង ប្រកបបានក្នុងចិត្ត ២៨ ដួង ដូចពោលមកហើយ តែ កេចិវាទ: ដែលបានដល់ សេចក្ដីយល់ឃើញរបស់អាចារ្យខ្លះសម្ដែងថា អប្បមញ្ញា ២ ដួងនេះ ប្រកបបានក្នុងចិត្ត ២០ ដួងប៉ុណ្ណោះ គឺ មហាកុសលសោមនស្ស ៤ មហាកិរិយាសោមនស្ស ៤ រូបាវចរចិត្ត ១២ (វៀរបញ្ចមជ្ឈានចិត្ត ៣) នឹងប្រកបក្នុងមហាកុសលឧបេក្ខា ៤ មហាកិរិយាឧបេក្ខា ៤ មិនបាន ដោយឲ្យហេតុផលថា **វិហឹស:** គឺការប្រទូសរាយបុគ្គលដទៃនោះ អង្គធម៌បានដល់ទោសចេតសិក សភាវ:របស់ករុណារមែងជាបដិបក្ខនឹងទោសចេតសិក **អរតិ** គឺសេចក្ដីមិនត្រេកអរ មិនពេញចិត្ត មិនសប្បាយចិត្ត ក្នុងសេចក្ដីល្អរបស់អ្នកដទៃ អង្គធម៌បានដល់ ទោមនស្សវេទនា ដែលមានឥស្សាជាប្រធាន សភាវ:របស់មុទិតា រមែងជាបដិបក្ខនឹកទោមនស្សវេទនា ដែលមានឥស្សាជាប្រធាន ដូច្នោះ ករុណា មុទិតា ទើបត្រូវប្រកបដោយសោមនស្សសហគតចិត្ត មិនគួរ

ប្រកបក្នុងឧបេក្ខាសហគតចិត្ត តែសមានវាទៈ គឺអដ្ឋកថាចារ្យទាំងឡាយពោលថា សេចក្តីយល់ឃើញរបស់កេចិអាចារ្យនេះ ត្រូវមួយផ្នែក ខុសមួយផ្នែក ដែលត្រូវមួយផ្នែកនោះ គឺអ្នកចម្រើនករុណា មុទិតាកម្មដ្ឋាន ក្នុងចំណែកខាងដើម កាលនៅជាបរិកម្មភាវនា និងបរិកម្មនិមត្ត មិនទាន់ដល់ឧគ្គហនិមិត្ត ករុណា មុទិតា នឹងកើតឡើងបានត្រូវដោយចិត្តជាសោមនស្សពិតៗ មិនដូច្នោះ ករុណា មុទិតាក៏មិនអាចកើតឡើងបាន ត្រង់នេះឯង ដែលថា ករុណា មុទិតា ត្រូវកើតក្នុងចិត្តដែលប្រកបដោយសោមនស្សទើបជាការត្រឹមត្រូវ ។ តែកាលចម្រើនករុណា មុទិតាកម្មដ្ឋាននោះតទៅ ចូលដល់ឧគ្គហនិមិត្តកើតឡើងហើយ រមែងសម្តែងថា ចិត្តរបស់អ្នកចម្រើនកម្មដ្ឋាននោះ មានភាពស្ទាត់ជំនាញក្នុងករុណា មុទិតាកម្មដ្ឋានជាយ៉ាងល្អហើយ ដូច្នោះ ក្នុងខណៈចម្រើនករុណា មុទិតាកម្មដ្ឋាន ដែលឧគ្គហនិមិត្តកំពុងកើតនោះ ចិត្តរបស់អ្នកនោះ មានភាពស្ទាត់ជំនាញដូចពោលមកហើយ ទើបអាចប្រកបដោយសោមនស្សវេទនា ឬឧបេក្ខាវេទនាក៏បាន មិនចាំបាច់ត្រូវជាសោមនស្សវេទនារហូតនោះទេ ដែលថាករុណា មុទិតា មិនកើតក្នុងចិត្តជាឧបេក្ខានោះ ទើបមិនត្រូវ ។

## អនិយតយោគី និងនិយតយោគីចេតសិក

ឥស្សាមច្ឆេរកុក្កុច្ច- វិរតិករុណាទយោ
នានា កទាចិ មានោ ច ថិនមិទ្ធំ តថា សហ ។

យថាវុត្តានុសារេន សេសា **និយតយោគិនោ**
**សង្គហញ្ច** បវក្ខាមិ តេសំ ទានិ យថារហំ ។

ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ វិរតិ ៣ ករុណា មុទិតា រួមជាចេតសិក ៨ ដួងនេះ ប្រកបបានពេលខ្លះ និងមិនប្រកបព្រមគ្នា ឈ្មោះថា **នានាកទាចិចេតសិក**, មានះក៏ប្រកបបានក្នុងពេលខ្លះ ឈ្មោះ **កទាចិចេតសិក**, ថិនៈ មិទ្ធៈ ទាំង ២ នេះ ប្រកបបានពេលខ្លះ តែកើតព្រមគ្នា ឈ្មោះថា **សហកទាចិចេតសិក**, ចេតសិកដែលនៅសល់ ៤១ ដួង ដែលដល់ពី ១១ ដួងនេះ ជាចេតសិកដែលប្រកបបានពិតប្រាកដឈ្មោះថា **និយតយោគីចេតសិក** (ឯចេតសិក ១១ ខាងដើមនោះឈ្មោះថា **អនិយតយោគីចេតសិក** ព្រោះប្រកបក្នុងចិត្តមិនពិតប្រាកដ) ។

## អធិប្បាយ

គាថានេះសម្ដែងអនិយតយោគីចេតសិក ១១ ដួង និងនិយតយោគីចេតសិក ៤១ ព្រមដោយបដិញ្ញានឹងសម្ដែងសង្គហន័យ ។

ការរាប់ចិត្តដែលចេតសិកប្រកប ដូចពោលមកហើយនេះ ចេតសិកពួកខ្លះប្រកបបានជានិច្ច មិនថាចិត្តនោះនឹងកើតឡើងក្នុងអារម្មណ៍ ដែលជាខាងក្នុងឬខាងក្រៅ និងមិនថាកិច្ចការណាៗ តែចេតសិកពួកខ្លះនោះនឹងកើតឡើងដោយមានអារម្មណ៍ជាចំពោះៗ មិនទូទៅ ដូច្នោះ ទើបប្រកបបានពេលខ្លះ ចេតសិកដែលមានអារម្មណ៍កំណត់ដោយចំពោះមាន ១១ ដួង ឈ្មោះថា **អនិយតយោគីចេតសិក** គឺ មានះ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ថិនៈ មិទ្ធៈ វិរតិ ៣ អប្បមញ្ញា ២ ។

មានចេតសិក ដែលពោលថា ប្រកបនឹងទិដ្ឋិគតវិប្បយុត្ត ៤ ដួងនោះ រមែងប្រកបមិនពិតប្រាកដ មានន័យថា វេលាណាទិដ្ឋិគតវិប្បយុត្តចិត្តកើតឡើងដោយប្រកាន់ខ្លួនថា **អហំតាហ** វេលានោះ មានចេតសិកក៏ប្រកបជាមួយ, វេលាណាទិដ្ឋិគតវិប្បយុត្តចិត្តកើតឡើង ដោយមិនមានសេចក្តីប្រកាន់ខ្លួន គឺ **អហំតាហ** ទេ វេលានោះ មានចេតសិកក៏មិនបានប្រកប ដូច្នោះ មានចេតសិកនេះទើបជា **កទាចិចេតសិក** ។

ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ទាំង ៣ ដួងនេះ ដែលពោលមកហើយថា ប្រកបក្នុងទោសមូលចិត្ត ២ ដួងនោះ រមែងប្រកបមិនពិតប្រាកដ និងចេតសិក ៣ ដួងនេះ សូម្បីមានឱកាសប្រកបក្នុងទោសមូលចិត្ត ក៏ប្រកបបានតែមួយដួងៗប៉ុណ្ណោះ នឹងប្រកបព្រមគ្នាមិនបាន ដែលប្រកបមិនពិតប្រាកដនោះមានន័យថា ពេលណាដែលទោសចិត្តកើតឡើងដោយមិនមានការច្រណែន សេចក្តីកំណាញ់ ឬការក្តៅក្រាហាយចិត្ត ក៏គង់មានត្រឹមតែទោសចិត្តកើតឡើងក្នុងអារម្មណ៍នោះប៉ុណ្ណោះ មិនបានប្រកបនឹងចេតសិកទាំង ៣ នេះទេ ។ វេលាណាដែលទោសចិត្តកើតឡើងដោយការច្រណែននឹងគុណសេចក្តីល្អរបស់អ្នកដទៃ វេលានោះទោសចិត្តកើតឡើងដោយមានឥស្សាចេតសិកប្រកបជាមួយ, មច្ឆរិយ និងកុក្កុច្ចៈមិនបានប្រកបឡើយ ។ វេលាណាទោសចិត្តកើត ឡើងដោយមានសេចក្តីកំណាញ់ក្នុងគុណសេចក្តីល្អរបស់ខ្លួន វេលានោះទោសចិត្តកើតឡើងដោយមានមច្ឆរិយចេតសិកប្រកបជាមួយ, ឥស្សា និងកុក្កុច្ចៈមិនបានប្រកបឡើយ ។ វេលាណា

ដែលទោសចិត្តកើតឡើងដោយមានការក្តៅក្រហាយចិត្ត ក្នុងទុច្ចរិតដែលបាន ធ្វើហើយ ឬការក្តៅក្រហាយចិត្តក្នុងសុចរិតដែលមិនបានធ្វើ វេលានោះទោសចិត្ត កើតឡើងដោយមានកុក្កុច្ចចេតសិកប្រកបជាមួយ, ឥស្សា និងមច្ឆរិយៈមិនបាន ប្រកបឡើយ ។

ថិនមិទ្ធចេតសិក ដែលបានពោលហើយមកថា ប្រកបក្នុងអកុសល-សសង្ខារិក ៥ ដួងនោះ ក៏ប្រកបបានដោយមិនពិតប្រាកដ ពេលណាដែល អកុសលសសង្ខារិកកើតឡើង និងថិនមិទ្ធចេតសិកក៏មានឱកាសចូលទៅប្រកប ហើយ ចេតសិកទាំង ២ ដួងនេះរមែងប្រកបព្រមគ្នាជានិច្ច ដែលពោលថា ប្រកប បានដោយមិនពិតប្រាកដនោះ មានន័យថា ក្នុងខណៈណាដែលអកុសល-សសង្ខារិកចិត្តកើតឡើង ជាចិត្តដែលរឹងរូស មិនរាថយ ពោលនោះថិនមិទ្ធៈ មិនចូលទៅប្រកបបានទេ បើអកុសលសសង្ខារិកចិត្តកើតឡើងមានការរាថយ មិនរឹងរូស ថិនមិទ្ធៈចូលទៅប្រកបបាន ។

វិរតិចេតសិក ៣ ដួងដែលប្រកបនឹងចិត្ត ១៦ ដួងឬ ៤៨ ដួងនេះ ជា អនិយតយោគីចេតសិក ឈ្មោះ **នានាកទាចិ** នោះ សំដៅយក **លោកិយវិរតិ-ចេតសិក** ប៉ុណ្ណោះ សម្រាប់ **លោកុត្តរវិរតិចេតសិក** នោះ ជា **និយតឯកតោ-ចេតសិក** គឺ ប្រកបបានយ៉ាងពិតប្រាកដ និងព្រមគ្នា ស្មើគ្នាជានិច្ច ដូចដែល អនុរុទ្ធាចារ្យសម្តែងទុកថា វិរតិយោ បន តិស្សោបិ លោកុត្តរចិត្តេសុ សព្វថាបិ និយតា ឯកតោវ លព្ភន្តិ, លោកិយេសុ បន កាមាវចរ-

កុសលេសុ កទាចិ សន្ទិស្សន្តិ វិសុំ វិសុំ ។ ប្រែថា វិរតិ ៣ ដួង កាលប្រកបក្នុងលោកុត្តរចិត្ត រមែងប្រកបបានដោយពិតប្រាកដ និងប្រកបព្រមគ្នាជានិច្ច (និយតឯកតោ) ក្នុងឋានៈដែលធ្វើនាទីប្រហារទុច្ចរិតមិច្ឆាអាជីវៈឲ្យដាច់ជាសមុច្ឆេទ, តែកាលប្រកបក្នុងលោកិយចិត្ត ពោលគឺ មហាកុសលចិត្តនោះ រមែងប្រកបបានត្រឹមតែពេលខ្លះ គ្រាខ្លះប៉ុណ្ណោះ ហើយប្រកបមិនព្រមគ្នាទៀតផង ។

ការដែលវិរតិចេតសិក ៣ ដួងនេះ ប្រកបក្នុងមហាកុសលចិត្តមិនពិតប្រាកដ និងមិនព្រមគ្នានោះ ព្រោះវេលាណាមហាកុសលចិត្តកើតឡើងដោយអាស្រ័យសទ្ធា សតិ បញ្ញា មេត្តា ករុណា មុទិតា ដែលមិនទាក់ទងនឹងការវៀរចាកទុច្ចរិតមិច្ឆាអាជីវៈ មហាកុសលចិត្តដែលកើតឡើងនោះ មិនមានវិរតិប្រកបឡើយ វេលាណាដែលមហាកុសលចិត្តកើតឡើង ដោយការវៀរចាកវចីទុច្ចរិត ៤ ដែលមិនទាក់ទងនឹងអាជីវៈ វេលានោះសម្មាវាចាចេតសិក ក៏បានប្រកបជាមួយ, សម្មាកម្មន្តៈ សម្មាអាជីវៈមិនប្រកបឡើយ ។ វេលាណាមហាកុសលចិត្តកើតឡើងដោយការវៀរចាកកាយទុច្ចរិត ៣ ដែលមិនទាក់ទងនឹងអាជីវៈ វេលានោះសម្មាកម្មន្តចេតសិកក៏ប្រកបជាមួយ, សម្មាវាចា សម្មាអាជីវៈមិនប្រកបឡើយ ។ វេលាណាមហាកុសលចិត្តកើតឡើងដោយការវៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលមានអាជីវៈជាប្រធាននោះ វេលានោះសម្មាអាជីវចេតសិកក៏បានប្រកបជាមួយ, សម្មាវាចា សម្មាកម្មន្តមិនប្រកបឡើយ ។

អប្បមញ្ញាចេតសិក ២ ដួង ដែលថាប្រកបក្នុងចិត្ត ២៨ ដួងដោយមិនពិតប្រាកដនោះ ព្រោះវេលាមហាកុសល មហាកិរិយាចិត្តកើតឡើងដោយអាស្រ័យសទ្ធា សតិ បញ្ញាជាដើម មិនបានអាស្រ័យករុណា មុទិតា វេលានោះមហាកុសលមហាកិរិយាចិត្តកើតឡើង អប្បមញ្ញាចេតសិកមិនបានប្រកបជាមួយឡើយ ។ វេលាណា រូបាវចរឈានចិត្តកើតឡើង ដោយអាស្រ័យការចម្រើនកម្មដ្ឋានដទៃៗមានកសិណកម្មដ្ឋានជាដើម មិនបានអាស្រ័យការចម្រើនអប្បមញ្ញាកម្មដ្ឋានវេលានោះរូបាវចរឈានចិត្តកើតឡើង ដោយមិនមានអប្បមញ្ញាចេតសិកប្រកបឡើយ ។ អប្បមញ្ញាចេតសិក ២ ដួងនេះ សូម្បីមានឱកាសប្រកបនឹងចិត្ត ២៨ ដួងក៏ប្រកបមិនព្រមគ្នា ពោលគឺ កាលចិត្ត ២៨ ដួងនេះ កើតឡើងដោយអាស្រ័យទុក្ខិតសត្តបញ្ញត្តិជាអារម្មណ៍ ឬជាកម្មដ្ឋាន ពេលនោះទើបមានករុណាចេតសិកប្រកប, មុទិតាចេតសិកមិនប្រកបឡើយ ។ វេលាណាចិត្ត ២៨ ដួងនេះ កើតឡើងដោយអាស្រ័យសុខិតសត្តបញ្ញត្តិជាអារម្មណ៍ ឬជាកម្មដ្ឋាន វេលានោះមុទិតា-ចេតសិកទើបចូលប្រកប តែករុណាចេតសិកមិនប្រកបឡើយ ។

## សង្គហន័យ

ឆត្តឹសានុត្តរេ ធម្មា បញ្ចតឹស មហគ្គតេ
អដ្ឋតឹសាបិ លព្ភន្តិ កាមាវចរសោភនេ ។

សត្តវីសតិបុញ្ញម្ហិ ទ្វាទសាហេតុកេតិ ច
យថាសម្ភវយោគេន បញ្ចធា តត្ថ សង្គហោ ។

សង្គហន័យ គឺការរាប់ចំនួនចេតសិកក្នុងចិត្ត ៨៩ ឬ ១២១ ដួងនោះមាន ៥ ប្រការ តាមសមគួរដែលប្រកបបាន គឺ

- ក្នុងលោកុត្តរចិត្ត មានចេតសិកប្រកបបាន ៣៦ បានដល់ អញ្ញសមាន-ចេតសិក ១៣ សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក ២) ។

- ក្នុងមហគ្គតចិត្ត មានចេតសិកប្រកប ៣៥ គឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២២ (វៀរវិរតិចេតសិក ៣) ។

- ក្នុងកាមាវចរសោភណចិត្ត មានចេតសិកប្រកបបាន ៣៨ គឺ អញ្ញសមាន-ចេតសិក ១៣ សោភណចេតសិក ២៥ ។

- ក្នុងអកុសលចិត្ត មានចេតសិកប្រកបបាន ២៧ បានដល់ អញ្ញសមាន-ចេតសិក ១៣ អកុសលចេតសិក ១៤ ។

- ក្នុងអហេតុកចិត្ត មានចេតសិកប្រកបបាន ១២ បានដល់ អញ្ញសមាន-ចេតសិក ១២ (វៀរឆន្ទចេតសិក) ។

## **អធិប្បាយ**

គាថាសម្តែងគោលរបស់សង្គហន័យដោយសង្ខេប ដើម្បីឲ្យអ្នកសិក្សាទាំងឡាយកាន់យកគោលជាមុន ហើយទើបអធិប្បាយសេចក្តីក្នុងសង្គហន័យដោយពិស្តារតទៅ ។

## អកុសលសង្គហៈ

## (សត្តវិសតិ បុញ្ញម្ហិ)

១. លោភមូលចិត្តដួងទី ១ មានចេតសិកប្រកប ១៩ ដួងគឺ អញ្ញសមានៈ ១៣ មោចតុក្កៈ ៤ លោភៈ ១ ទិដ្ឋិ ១ ។

២. លោភមូលចិត្តដួងទី ២ មានចេតសិកប្រកប ២១ ដួង គឺ អញ្ញសមានៈ ១៣ មោចតុក្កៈ ៤ លោភៈ ១ ទិដ្ឋិ ១ ថិទុកៈ ២ ។

៣. លោភមូលចិត្តដួងទី ៣ មានចេតសិកប្រកប ១៩ ដួង គឺ អញ្ញសមានៈ ១៣ មោចតុក្កៈ ៤ លោភៈ ១ មានះ ១ ។

៤. លោភមូលចិត្តដួងទី ៤ មានចេតសិកប្រកប ២១ ដួងគឺ អញ្ញសមានៈ ១៣ មោចតុក្កៈ ៤ លោភៈ ១ មានះ ១ ថិទុកៈ ២ ។

៥. លោភមូលចិត្តដួងទី ៥ មានចេតសិកប្រកប ១៨ ដួង គឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុក្កៈ ៤ លោភៈ ១ ទិដ្ឋិ ១ ។

៦. លោភមូលចិត្តដួងទី ៦ មានចេតសិកប្រកប ២០ ដួង គឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុកៈ ៤ លោភៈ ១ ទិដ្ឋិ ១ ថិទុកៈ ២

៧. លោភមូលចិត្តដួងទី ៧ មានចេតសិកប្រកប ១៨ ដួងគឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុក្កៈ ៤ លោភៈ ១ មានះ ១ ។

៨. លោភមូលចិត្តដួងទី ៨ មានចេតសិកប្រកប ២០ ដួង គឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុក្កៈ ៤ លោភៈ ១ មានះ ១ ថិទុកៈ ២ ។

៩. ទោសមូលចិត្តដួងទី ១ មានចេតសិកប្រកប ២០ ដួងគឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុក្កៈ ៤ ទោចតុក្កៈ ៤ ។

១០. ទោសមូលចិត្តដួងទី ២ មានចេតសិកប្រកប ២២ ដួងគឺ អញ្ញសមានៈ ១២ (វៀរបីតិ) មោចតុក្កៈ ៤ ទោចតុក្កៈ ៤ ថិទុកៈ ២ ។

១១. មោហមូលចិត្តដួងទី ១ មានចេតសិកប្រកប ១៥ ដួង គឺ អញ្ញសមានៈ ១០ (វៀរអធិមោក្ខៈ បីតិ ឆន្ទៈ) មោចតុក្កៈ ៤ វិចិកិច្ឆា ១ ។

១២. មោហមូលចិត្តដួងទី ២ មានចេតសិកប្រកប ១៥ ដួងគឺ អញ្ញសមានៈ ១១ (វៀរបីតិឆន្ទៈ) មោចតុក្កៈ ៤ ។

## គាថាសម្តែងសង្គហន័យ ៧ ន័យក្នុងអកុសលចិត្ត ១២

ឯកូនវីសាដ្ឋារស　　　　វីសេកវីស វីសតិ
ទ្វាវីស បន្នរសេតិ　　　　សត្តធា កុសលេដិតា ។

ក្នុងអកុសលចិត្ត ១២ មានសង្គហន័យ ៧ ន័យ គឺ

- ចំនួនចេតសិក ១៩ ដួង ដែលប្រកបក្នុងបឋមអសង្ខារិកនិងទុតិយអសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ១៨ ដួង ដែលប្រកបក្នុងតតិយអសង្ខារិក និងចតុត្ថអសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ២០ ដួង ដែលប្រកបក្នុងបញ្ចមអសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ២១ ដួង ដែលប្រកបក្នុងបឋមសសង្ខារិកនិងទុតិយ-សសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ២០ ដួង ដែលប្រកបក្នុងតតិយសសង្ខារិកនិងចតុត្ថ-សសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ២២ ដួង ដែលប្រកបក្នុងបញ្ចមសសង្ខារិក រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ១៥ ដួង ដែលប្រកបក្នុងមោហមូលចិត្ត ២ រាប់ជា ១ ន័យ ។

## គាថាសម្ដែងសព្វាកុសលយោគីចេតសិក ១៤

គឺចេតសិកដែលប្រកបក្នុងអកុសលចិត្តបានទាំងអស់

សាធារណា ច ចត្តារោ សមានា ច ទសាបរេ

ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសលយោគិនោ ។

សព្វាកុសលសាធារណចេតសិក (មោចតុក្កៈ) ៤ អញ្ញសមានចេតសិក ១០ (អធិមោក្ខៈ បីតិ ឆន្ទៈ) រួមជា ១៤ នេះ ហៅថា សព្វាកុសលយោគីចេតសិក គឺជាចេតសិកដែលប្រកបក្នុងអកុសលចិត្តទាំង ១២ ដួង បានទាំងអស់ ។

## អហេតុកសង្គហន័យ

(ទ្វាទសាហេតុកេ)

ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មានចេតសិកប្រកប ៧ ដួងគឺ សព្វចិត្តសាធារណ-ចេតសិក ៧ ។

សម្បដិច្ឆនចិត្ត ២ ឧបេក្ខាសន្តិរណចិត្ត ២ បញ្ចទ្វារាវជ្ជនចិត្ត ១ ទាំង ៥ ដួងនេះ មានចេតសិកប្រកប ១០ ដួងគឺ អញ្ញសមានចេតសិក ១០ (វៀរវីរិយៈ បីតិ ឆន្ទៈ) ។

សោមនស្សសន្តីរណចិត្ត មានចេតសិកប្រកប ១១ ដួងគឺ អញ្ញសមាន-ចេតសិក ១១ (វៀរវីរិយៈ ឆន្ទៈ) ។

មនោទ្វារាវជ្ជនចិត្ត មានចេតសិកប្រកប ១១ ដួងគឺអញ្ញសមានចេតសិក ១១ (វៀរ បីតិ ឆន្ទៈ) ។

ហសិតុប្បាទចិត្ត មានចេតសិកប្រកប ១២ គឺ អញ្ញសមានចេតសិក ១២ (វៀរ ឆន្ទៈ) ។

**គាថាសម្ដែងសង្គហន័យ ៤ ន័យក្នុងអហេតុកចិត្ត ១៨**

ទ្វាទសេកាទស ទស សត្ត ចាតិ ចតុព្វិធោ
អដ្ឋារសាហេតុកេសុ ចិត្តុប្បាទេសុ សង្គហោ ។

ក្នុងអហេតុកចិត្ត ១៨ មានសង្គហន័យ ៤ ន័យ គឺ

១. ចំនួនចេតសិក ១២ ដួង ដែលប្រកបក្នុងហសិតុប្បាទចិត្ត រាប់ជា ១ ន័យ ។

២. ចំនួនចេតសិក ១១ ដួង ដែលប្រកបក្នុងសោមនស្សសន្តីរណចិត្ត និង មនោទ្វារាវជ្ជនចិត្ត រាប់ជា ១ ន័យ ។

៣. ចំនួនចេតសិក ១០ ដួង ដែលប្រកបក្នុងមនោធាតុ ៣ រាប់ជា ១ ន័យ ។

៤. ចំនួនចេតសិក ៧ ដួង ដែលប្រកបក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ១០ រាប់ជា ១ ន័យ ។

## កាមាវចរសោភណសង្គហន័យ

## (អដ្ឋតឹសាបិ លព្ភន្តិ កាមាវចរសោភណេ)

មហាកុសលចិត្តដួងទី ១ និងដួងទី ២ មានចេតសិកប្រកប ៣៨ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២៥ ។

មហាកុសលចិត្តដួងទី ៣ និងទី ៤ មានចេតសិកប្រកប ៣៧ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២៤ (វៀរបញ្ញា) ។

មហាកុសលចិត្តដួងទី ៥ ដួងទី ៦ មានចេតសិកប្រកប ៣៧ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណចេតសិក ២៥ ។

មហាកុសលចិត្តដួងទី ៧ ដួងទី ៨ មានចេតសិកប្រកប ៣៦ គឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណចេតសិក ២៤ (វៀរបញ្ញា) ។

សរុបចេតសិកដែលប្រកបក្នុងមហាកុសលចិត្តទាំងអស់មាន ៣៨ ដួង ។

មហាវិបាកចិត្តដួងទី ១ និងដួងទី ២ មានចេតសិកប្រកប ៣៣ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណសាធារណចេតសិក ១៩ បញ្ញា ១ ។

មហាវិបាកចិត្តដួងទី ៣ និងទី ៤ មានចេតសិកប្រកប ៣២ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណសាធារណចេតសិក ១៩ ។

មហាវិបាកចិត្តដួងទី ៥ ទី ៦ មានចេតសិកប្រកប ៣២ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណសាធារណចេតសិក ១៩ បញ្ញា ១ ។

មហាវិបាកចិត្តដួងទី ៧ ទី ៨ មានចេតសិកប្រកប ៣១ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណសាធារណចេតសិក ១៩ ។

សរុបចេតសិកដែលប្រកបក្នុងមហាវិបាកចិត្តទាំងអស់មានចំនួន ៣៣ ដួង។

មហាកិរិយាចិត្តដួងទី ១ ទី ២ មានចេតសិកប្រកប ៣៥ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

មហាកិរិយាចិត្តដួងទី ៣ ទី ៤ មានចេតសិកប្រកប ៣៤ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២១ (វៀរវិរតិ ៣ បញ្ញា ១) ។

មហាកិរិយាចិត្តដួងទី ៥ ទី ៦ មានចេតសិកប្រកប ៣៤ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

មហាកិរិយាចិត្តដួងទី ៧ ទី ៨ មានចេតសិកប្រកប ៣៣ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) សោភណចេតសិក ២១ (វៀរវិរតិ ៣ បញ្ញា ១ ) ។

សរុបចេតសិកដែលប្រកបក្នុងមហាកិរិយាចិត្តទាំងអស់ ៣៥ ដួង ។

**គាថាសង្គហៈសម្ដែងសង្គហន័យ ១២ ន័យ**

**ក្នុងកាមាវចរសោភណចិត្ត ២៤**

អដ្ឋតឹស សត្តតឹស      ទ្វយំ ឆត្តឹសកំ សុភេ
បញ្ចតឹស ចតុត្តឹស      ទ្វយំ តេត្តឹសកំ ក្រិយេ ។

តេត្តឹស ចាគោ ពាត្តឹស ទ្វយេកតឹសកំ ភវេ
សហេតុកាមាវចរបុញ្ញ- ចាកក្រិយាមនេ ។

បណ្ដាកាមាវចរកុសល សហេតុកកាមាវចរវិបាក សហេតុកកាមាវចរ-កិរិយាចិត្តនោះ សម្រាប់កាមាវចរកុសលចិត្ត ៨ ដួង មាន ៤ ន័យ គឺ

ចំនួនចេតសិក ៣៨ ដែលប្រកបក្នុងចិត្តដួងទី ១ និងទី ២ រាប់ជា ១ ន័យ ។

ចំនួនចេតសិក ៣៧ ទាំងគូ ដែលប្រកបក្នុងចិត្តដួងទី ៣ ទី ៤ និងទី ៥ ទី ៦ រាប់ជា ២ ន័យ ។

ចំនួនចេតសិក ៣៦ ដែលប្រកបក្នុងចិត្តដួងទី ៧ និងទី ៨ រាប់ជា ១ ន័យ ។

ក្នុងសហេតុកកាមាវចរកិរិយាចិត្ត ៨ ដួង មានសង្គហន័យ ៤ ន័យ គឺ

ចំនួនចេតសិក ៣៥ ដែលប្រកបក្នុងចិត្តដួងទី ១ និងទី ២ រាប់ជា ១ ន័យ ។

ចំនួនចេតសិក ៣៤ ទាំងគូ ដែលប្រកបក្នុងចិត្តដួងទី ៣ ទី ៤ និងទី ៥ ទី ៦ រាប់ជា ២ ន័យ ។

ចំនួនចេតសិក ៣៣ ដែលប្រកបក្នុងចិត្តដួងទី ៧ និងទី ៨ រាប់ជា ១ ន័យ ។

ក្នុងសហេតុកកាមាវចរវិបាកចិត្ត ៨ ដួង មានសង្គហន័យ ៤ ន័យ គឺ

ចំនួនចេតសិក ៣៣ ដែលប្រកបក្នុងចិត្តដួងទី ១ និងទី ២ រាប់ជា ១ ន័យ ។

ចំនួនចេតសិក ៣២ ទាំងគូ ដែលប្រកបក្នុងចិត្តដួងទី ៣ ទី ៤ និងទី ៥ ទី ៦ រាប់ជា ២ ន័យ ។

ចំនួនចេតសិក ៣១ ដែលប្រកបក្នុងចិត្តដួងទី ៧ និងទី ៨ រាប់ជា ១ ន័យ ។

## មហគ្គតសង្គហន័យ

(បញ្ចតឹស មហគ្គតេ)

បឋមជ្ឈានចិត្ត ៣ ដួងមានចេតសិកប្រកប ៣៥ ដួង គឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

ទុតិយជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣៤ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរវិតក្កៈ) សោភណចិត្ត ២២ (វៀរវិរតិ ៣) ។

តតិយជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣៣ ដួងគឺ អញ្ញសមានចេតសិក ១១ (វៀរវិតក្កៈ វិចារៈ) សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

ចតុត្ថជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣២ ដួងគឺ អញ្ញសមានចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ) សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

បញ្ចមជ្ឈានចិត្ត ១៥ មានចេតសិកប្រកប ៣០ ដួងគឺ អញ្ញសមានចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ) សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

### គាថាសង្គហៈសម្តែងសង្គហន័យ ៥ ន័យក្នុងមហគ្គតចិត្ត ២៧

បញ្ចតឹស ចតុត្តឹស  តេត្តឹស ច យថាក្កមំ

ពាត្តឹស ចេវ តឹសេតិ  បញ្ចធាវ មហគ្គតេ ។

ក្នុងមហគ្គតចិត្ត ២៧ មានសង្គហន័យ ៥ ន័យ គឺ

- ចំនួនចេតសិក ៣៥ ដែលប្រកបក្នុងបឋមជ្ឈានចិត្ត រាប់ជា ១ ន័យ ។
- ចំនួនចេតសិក ៣៤ ដែលប្រកបក្នុងទុតិយជ្ឈានចិត្ត រាប់ជា ១ ន័យ ។
- ចំនួនចេតសិក ៣៣ ដែលប្រកបក្នុងតតិយជ្ឈានចិត្ត រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ៣២ ដែលប្រកបក្នុងចតុត្ថជ្ឈានចិត្ត រាប់ជា ១ ន័យ ។
- ចំនួនចេតសិក ៣០ ដែលប្រកបក្នុងបញ្ចមជ្ឈានចិត្ត រាប់ជា ១ ន័យ ។

## លោកុត្តរសង្គហន័យ

(ឆត្តឹសានុត្តរេ ធម្មា)

បឋមជ្ឈានចិត្ត ៨ មានចេតសិកប្រកប ៣៦ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

ទុតិយជ្ឈានចិត្ត ៨ ដួង មានចេតសិកប្រកប ៣៥ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរវិតក្កៈ) សោភណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

តតិយជ្ឈានចិត្ត ៨ ដួង មានចេតសិកប្រកប ៣៤ ដួងគឺ អញ្ញសមានចេតសិក ១១ (វៀរវិតក្កៈ វិចារៈ) សោភណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

ចតុត្ថជ្ឈានចិត្ត ៨ ដួងនិងបញ្ចមជ្ឈានចិត្ត ៨ ដួង មានចេតសិកប្រកប ៣៣ ដួង គឺអញ្ញសមានចេតសិក ១០ (វៀរវិរតក្កៈ វិចារៈ បីតិ) សោភណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

### គាថាសង្គហៈសម្ដែងសង្គហន័យ ៥ ន័យក្នុងលោកុត្តរចិត្ត ៤០

ឆត្តឹស បញ្ចតឹសា ច ចតុត្តឹស យថាក្កមំ
តេត្តឹស ទ្វយមិច្ចេវំ បញ្ចធានុត្តរេ ឋិតា ។

ក្នុងលោកុត្តរចិត្ត ៤០ មានសង្គហន័យ ៥ ន័យ គឺ

- ចំនួនចេតសិក ៣៦ ដែលប្រកបក្នុងបឋមជ្ឈានចិត្ត ៨ រាប់ជា ១ ន័យ ។

- ចំនួនចេតសិក ៣៥ ដែលប្រកបក្នុងទុតិយជ្ឈានចិត្ត ៨ រាប់ជា ១ ន័យ ។
- ចំនួនចេតសិក ៣៤ ដែលប្រកបក្នុងតតិយជ្ឈានចិត្ត ៨ រាប់ជា ១ ន័យ ។
- ចំនួនចេតសិក ៣៣ ទាំងគូ ដែលប្រកបក្នុងចតុត្ថជ្ឈានចិត្ត ៨ និង បញ្ចមជ្ឈានចិត្ត ៨ រាប់ជា ២ ន័យ ។

## សម្តែងសេចក្តីខុសគ្នារបស់វេទនាចេតសិក ដែលប្រកបនឹងឈានចិត្តទាំង ៥

វេទនាចេតសិកដែលប្រកបនឹងបឋមជ្ឈានចិត្ត ទុតិយជ្ឈានចិត្ត តតិយជ្ឈាន-ចិត្ត ចតុត្ថជ្ឈានចិត្ត ជាសោមនស្សវេទនា វេទនាចេតសិកដែលប្រកបនឹង បញ្ចមជ្ឈានចិត្តនោះជាឧបេក្ខាវេទនា ។

## គាថាសម្តែងសោភណចេតសិកដែលមិនប្រកបនឹងសោភណចិត្តពួកខ្លះ

ន វិជ្ជន្តេត្ថ វិរតី ក្រិយេសុ ច មហគ្គតេ
អនុត្តរេ អប្បមញ្ញា កាមបាកេ ទ្វយំ តថា ។

ក្នុងចំនួនសោភណចិត្ត ៩១ នោះ សម្រាប់មហាកិរិយាចិត្ត និងមហគ្គតចិត្ត វិរតិចេតសិករមែងមិនប្រកប, ក្នុងលោកុត្តរចិត្ត អប្បមញ្ញាចេតសិក ២ រមែងមិន ប្រកប, ចំណែកមហាវិបាកចិត្តនោះ ទាំងវិរតិចេតសិក ៣ និងអប្បមញ្ញាចេតសិក ២ រមែងមិនប្រកប ។

## ហេតុផលដែលវិរតិចេតសិក ៣ មិនប្រកបក្នុងមហាវិបាកនិងមហាកិរិយាចិត្ត

*វិរតិចេតសិក ៣ ដែលកើតឡើងដោយវៀរចាកអំពើទុច្ចរិតជាតទង្គៈក្នុងលោកិយៈនោះ រមែងជានាទីរបស់កុសលជាតិ មិនមែនជានាទីរបស់វិបាកជាតិ ឬកិរិយាជាតិទេ ដោយហេតុនេះ វិរតិចេតសិក ៣ ដូងនេះ ទើបមិនប្រកបក្នុងមហាវិបាកចិត្ត និងមហាកិរិយាចិត្ត ។*

## សម្តែងហេតុផលដែលវិរតិចេតសិក ៣ មិនប្រកបនឹងមហគ្គតចិត្ត

*មហគ្គតកុសល និងមហគ្គតកិរិយា រមែងកើតឡើងអាស្រ័យបរិកម្មសមាធិ ឧបចារសមាធិដែលកើតអំពីបរិកម្មភាវនា ឧបចារភាវនា ដែលមានកម្មដ្ឋានជាអារម្មណ៍ មិនកើតឡើងដោយអាស្រ័យការវៀរចាកអំពីទុច្ចរិត ដែលត្រូវមានវិរមិតព្វវត្ថុជាអារម្មណ៍ឡើយ សម្រាប់មហគ្គតិវិបាកនោះ ជាផលរបស់មហគ្គត-កុសល ទើបត្រូវប្រព្រឹត្តទៅតាមមហគ្គតកុសលគ្រប់ប្រការ ។*

## ហេតុផលដែលអប្បមញ្ញាចេតសិកមិនប្រកបនឹងមហាវិបាកចិត្ត និងលោកុត្តរចិត្ត

*អប្បមញ្ញាចេតសិក ២ ដួង គឺសេចក្តីអាណិតនិងសេចក្តីត្រេកអរដល់សត្វទាំងឡាយដែលកំពុងបានទទួលសេចក្តីទុក្ខ និងសេចក្តីសុខនោះ ធម្មជាតិរបស់សេចក្តីអាណិត និងសេចក្តីត្រេកអរដល់អ្នកដទៃត្រូវមានសត្វបញ្ញត្តិអារម្មណ៍ សម្រាប់មហាវិបាកចិត្តនោះ កើតឡើងត្រូវអាស្រ័យបរមត្ថ ដែលជាកាមារម្មណ៍ ឯលោកុត្តរចិត្តនឹងកើតឡើងបាន ក៏ត្រូវមាននិព្វានជាអារម្មណ៍ មិនមែនមាន*

សត្វបញ្ញត្តិជាអារម្មណ៍ ដូច្នោះ អប្បមញ្ញាចេតសិក ២ ដួង រមែងមិនប្រកបក្នុង មហាវិបាកចិត្ត និងលោកុត្តរចិត្តឡើយ ។

## គាថាសម្ដែងចេតសិកដែលធ្វើឲ្យចិត្តផ្សេងគ្នា

អនុត្តរេ ឈានធម្មា អប្បមញ្ញា ច មជ្ឈិមេ
វិរតី ញាណបីតី ច បរិត្តេសុ វិសេសកា ។

ក្នុងលោកុត្តរចិត្ត អង្គឈានទាំង ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា រមែងធ្វើឲ្យផ្សេងគ្នា ក្នុងមហគ្គតចិត្ត, អប្បមញ្ញាចេតសិក ២ និងអង្គឈានទាំង ៥ រមែងធ្វើឲ្យផ្សេងគ្នា ក្នុងកាមាវចរសោភណចិត្ត, វិរតិចេតសិក ៣ បញ្ញាចេតសិក ១ បីតិចេតសិក ១ អប្បមញ្ញាចេតសិក ២ រមែងធ្វើឲ្យផ្សេងគ្នា ។

## អធិប្បាយ

ក្នុងលោកុត្តរចិត្ត អង្គឈានទាំង ៥ ធ្វើឲ្យផ្សេងគ្នានោះ គឺវិតក្កចេតសិកធ្វើឲ្យបឋមជ្ឈានចិត្តផ្សេងគ្នា ពីឈានដទៃៗ ដ៏សេស វិចារចេតសិកធ្វើឲ្យទុតិយជ្ឈានចិត្តផ្សេងគ្នាពីឈានចិត្ត ៣ ដែលនៅសល់ បីតិចេតសិកធ្វើឲ្យតតិយជ្ឈានចិត្តផ្សេងគ្នាពីចតុត្ថជ្ឈានចិត្ត និងបញ្ចមជ្ឈានចិត្ត សុខវេទនាធ្វើឲ្យចតុត្ថជ្ឈានចិត្តផ្សេងគ្នាពីបញ្ចមជ្ឈានចិត្ត ឧបេក្ខាវេទនាធ្វើឲ្យបញ្ចមជ្ឈានផ្សេងគ្នាពីឈានចិត្តដ៏សេស ៤ ។

ក្នុងមហគ្គតចិត្ត អប្បមញ្ញាចេតសិក ២ ធ្វើឲ្យមហគ្គតចិត្តចិត្ត ១២ គឺ បឋមជ្ឈានរហូតដល់ចតុត្ថជ្ឈានផ្សេងពីគ្នាពីបញ្ចមជ្ឈានចិត្ត ១៥ ចំណែកអង្គឈានទាំង ៥ រមែងធ្វើឲ្យមហគ្គតចិត្តផ្សេងគ្នា ដូចនឹងលោកុត្តរចិត្តដែរ ។

ក្នុងកាមាវចរសោភណចិត្ត វិរតិចេតសិក ៣ ធ្វើឲ្យមហាកុសលចិត្តផ្សេងគ្នាពីមហាវិបាក និងមហាកិរិយា បញ្ញាចេតសិកធ្វើឲ្យញាណសម្បយុត្តចិត្តផ្សេងគ្នាពីញាណវិប្បយុត្តចិត្ត បីតិចេតសិកធ្វើឲ្យសោមនស្សសហគចិត្ត ផ្សេងគ្នាពីឧបេក្ខាសហគតចិត្ត អប្បមញ្ញាចេតសិក ២ ធ្វើឲ្យមហាកុសលចិត្ត និងមហាកិរិយាចិត្តផ្សេងគ្នាពីមហាវិបាកចិត្ត ។

## តទុភយមិស្សកន័យគឺសម្បយោគន័យនិងសង្គហន័យរួមគ្នា អញ្ញសមានរាសី

***ផស្សៈ*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ព្រោះពោលតាមសម្ប-យោគន័យ ផស្សៈនេះប្រកបក្នុងចិត្តទាំងអស់ ក្នុងចិត្តទាំងអស់ដែលផស្សៈប្រកបបាននេះ កាលពោលតាមសង្គហន័យ រមែងមានចេតសិក ៥២ ប្រកបបានតាមសមគួរ ដូច្នោះ ចេតសិកដែលប្រកបនឹងផស្សៈបានទើបមានតែ ៥១ (វៀរខ្លួនឯង) ឯសព្វចិត្តសាធារណចេតសិកដទៃដែលនៅសល់ ក៏មានទំនងដូចគ្នានេះ គឺ

***វេទនា*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

***សញ្ញា*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

***ចេតនា*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

***ឯកគ្គតា*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

***ជីវិតិន្ទ្រិយ*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

***មនសិការៈ*** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

**វិតក្កៈ** មានចេតសិក ៥១ (វៀរខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគ-ន័យ វិតក្កចេតសិកនេះប្រកបបាន ៥៥ ដួង ក្នុងចិត្ត ៥៥ ដួងនេះ កាលពោលតាមសង្គហន័យ រមែងមានចេតសិកប្រកប ៥២ តាមសមគួរ ដូច្នោះ ចេតសិកដែលប្រកបនឹងវិតក្កៈបាន ទើបមាន ៥១ (វៀរខ្លួនឯង) បកិណ្ណកចេតសិកដទៃៗ ដែលនៅសល់ ក៏ប្រព្រឹត្តទៅទំនងដូចគ្នាតាមសម្បយោគន័យ និងសង្គហន័យ នោះឯង គឺ

**វិចារៈ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

**អធិមោក្ខៈ** មានចេតសិកប្រកប ៥០ (វៀរវិចិកិច្ឆា និងខ្លួនឯង) ។

**វីរយៈ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

**បីតិ** មានចេតសិកប្រកប ៤៥ (វៀរទោចតុក្កៈ ៤ វិចិកិច្ឆា និងខ្លួនឯង) ។

**ឆន្ទៈ** មានចេតសិកប្រកប ៥០ (វៀរវិចិកិច្ឆា និងខ្លួនឯង) ។

## អកុសលរាសី

**មោហៈ** មានចេតសិកប្រកប ២៦ គឺ អញ្ញសមានចេតសិក ១៣ អកុសលចេតសិក ១៣ (វៀរខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគន័យ មោហៈនេះប្រកបក្នុងអកុសលចិត្តទាំងអស់ ក្នុងអកុសលចិត្តទាំងអស់ដែលមោហៈប្រកបបាននេះ កាលពោលតាមសង្គហន័យ រមែងមានចេតសិកប្រកបបាន ២៧ តាមសមគួរ ដូច្នោះ ចេតសិកដែលប្រកបនឹងមោហៈបាន ទើបមាន ២៦ (វៀរខ្លួនឯង) ក្នុងមោចតុក្កចេតសិកដ៏សេស ៣ ទៀត ក៏ប្រព្រឹត្តទមានទំនងដូចគ្នានេះ គឺ

***អហិរិកៈ*** *មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។*

***អនោត្តប្បៈ*** *មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។*

***ឧទ្ធច្ចៈ*** *មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។*

***លោភៈ*** *មានចេតសិកប្រកប ២១ គឺ អញ្ញសមានចេតសិក ១៣ អកុសល-ចេតសិក ៨ (វៀរទោចតុក្កៈ ៤ វិចិកិច្ឆា ១ និងខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគន័យ លោភចេតសិកនេះប្រកបក្នុងលោភមូលចិត្ត ៨ ក្នុងលោភ-មូលចិត្ត ៨ នេះ កាលពោលតាមសង្គហន័យ រមែងមានចេតសិកប្រកបបាន ២២ តាមសមគួរ ដូច្នោះ ចេតសិកដែលប្រកបនឹងលោភៈបាន ទើបមាន ២១ (វៀរខ្លួនឯង) ក្នុងលោភិកចេតសិកដ៏សេស ២ ទៀត ក៏ប្រព្រឹត្តទមានទំនងដូចគ្នានេះ គឺ*

***ទិដ្ឋិ*** *មានចេតសិកប្រកប ២០ (វៀរមានះ និងខ្លួនឯង) ។*

***មានះ*** *មានចេតសិកប្រកប ២០ (វៀរទិដ្ឋិ និងខ្លួនឯង) ។*

***ទោសៈ*** *មានចេតសិកប្រកប ២១ គឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) អកុសលចេតសិក ៩ (វៀរលោភិកៈ ៣ វិចិកិច្ឆា ១ និងខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគន័យ ទោសចេតសិកនេះប្រកបក្នុងទោសមូលចិត្ត ២ ក្នុងទោស-មូលចិត្ត ២ នេះ កាលពោលតាមសង្គហន័យ រមែងមានចេតសិកប្រកបបាន ២២ ដូច្នោះ ចេតសិកដែលប្រកបនឹងទោសៈបាន ទើបមាន ២១ (វៀរខ្លួនឯង) ។*

***ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ*** *៣ ដួងនេះមានចេតសិកប្រកបដួងមួយៗ ១៩ ដួងគឺ អញ្ញសមានចេតសិក ១២ (វៀរបីតិ) មោចតុក្កៈ ៤ ទោសៈ ១ ថិទុកៈ ២ ចេតសិក ៣ ដួងនេះ កាលពោលតាមសម្បយោគន័យ រមែងប្រកបបាននឹងទោសមូលចិត្ត ២ ដូចគ្នា ដូច្នោះ ចំនួនចេតសិកដែលប្រកបក៏គួរត្រូវជា ២១ (វៀរខ្លួនឯង) ដូចគ្នា តែចំនួនចេតសិកប្រកបបានត្រឹមតែ ១៩ នោះ ក៏ព្រោះចេតសិក ៣ ដួងនេះ ជានានាកទាចិ មិនកើតរួមគ្នាឡើយ ដូច្នោះ ចេតសិកដែលប្រកបនឹងចេតសិក ៣ ដួងនេះ មួយដួងៗ មាន ១៩ ។*

***ថិទុកចេតសិក*** *២ ក្នុងមួយដួងៗ មានចេតសិកប្រកប ២៥ គឺ អញ្ញសមាន-ចេតសិក ១៣ អកុសលចេតសិក ១២ (វៀរវិចិកិច្ឆា និងខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគន័យ ចេតសិក ២ ដួងនេះ រមែងប្រកបក្នុងអកុសល-សសង្ខារិកចិត្ត ៥ ក្នុងអកុសលសសង្ខារិកចិត្ត ៥ នេះ កាលពោលតាមសង្គហន័យមានចេតសិកប្រកប ២៦ ដូច្នោះ ចេតសិកដែលប្រកបនឹងថិទុកៈ ២ នេះ ក្នុងមួយដួងៗ ទើបមាន ២៥ (វៀរខ្លួនឯង) ។*

***វិចិកិច្ឆាចេតសិក*** *មានចេតសិកប្រកប ១៤ គឺ អញ្ញសមានចេតសិក ១០ (វៀរអធិមោក្ខៈ បីតិ ឆន្ទៈ) មោចតុក្កៈ ៤ រួមជា ១៤ ។*

## សោភណរាសី

***សោភណសាធារណចេតសិក ១៩*** *ក្នុងមួយដួងៗ មានចេតសិកប្រកប ៣៧ គឺ អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២៤ (វៀរខ្លួនឯង) ។*

***វិរតិចេតសិក ៣ ជាលោកិយៈ*** *មានចេតសិកប្រកប ៣៣ គឺ អញ្ញសមាន-ចេតសិក ១៣ សោភណសារណចេតសិក ១៩ បញ្ញា ១ ។ លោកិយវិរតិចេតសិក ៣ នេះ ប្រកបក្នុងមហាកុសលចិត្ត ក្នុងមហាកុសលចិត្តមានចេតសិកប្រកប ៣៨ ប៉ុន្តែវិរតិចេតសិក ៣ ដួងនេះ ក្នុងមួយដួងៗ មានចេតសិកប្រកបត្រឹមតែ ៣៣ ប៉ុណ្ណោះ ព្រោះវិរតិចេតសិក ៣ និងអប្បមញ្ញាចេតសិក ២ រួមជា ៥ ដួងនេះ មិនកើតព្រមគ្នា ទើបត្រូវវៀរចេញ ។*

***វិរតិចេតសិក ៣ ជាលោកុត្តរៈ*** *មានចេតសិកប្រកបមួយដួងៗ ៣៥ គឺ អញ្ញសមានចេតសិក ១៣ សោភណសាធារណចេតសិក ១៩ វិរតិ ២ (វៀរខ្លួនឯង) បញ្ញា ១ សម្រាប់លោកុត្តរវិរតិចេតសិក ៣ ដួងនេះ រមែងប្រកបពិតប្រាកដ និងកើតព្រមគ្នា ឈ្មោះថា* **និយតឯកតោ** *ក្នុងលោកុត្តរចិត្តនេះ មានចេតសិកប្រកប ៣៦ ដូច្នោះ លោកុត្តរវិរតិចេតសិក ៣ នេះ ក្នុងមួយដួងៗ មានចេតសិកប្រកប ៣៥ (វៀរខ្លួនឯង) ។*

***អប្បមញ្ញាចេតសិក ២*** *ក្នុងមួយដួងៗ មានចេតសិកប្រកប ៣៣ គឺ អញ្ញសមានចេតសិក ១៣ សោភណសាធារណៈ ១៩ បញ្ញា ១ ។ អប្បមញ្ញា-ចេតសិក ២ ដួងនេះប្រកបក្នុងចិត្តបាន ២៨ ដួង គឺ មហាកុសលចិត្តជាដើម ក្នុងចិត្ត ២៨ ដួងនោះមានចេតសិកប្រកប ៣៨ តែដែលអប្បមញ្ញាចេតសិក មានចេតសិកប្រកបមួយដួងៗ ត្រឹមតែ ៣៣ នោះ ក៏ព្រោះវិរតិ ៣ និងអប្បមញ្ញា ២ រួមជាចេតសិក ៥ ដួងនេះ មិនកើតព្រមគ្នា ទើបត្រូវវៀរចេញ ។*

**បញ្ញាចេតសិក** មានចេតសិកប្រកប ៣៧ ដួងគឺ អញ្ញសមានចេតសិក ១៣ សោភណសាធារណចេតសិក ២៤ (វៀរខ្លួនឯង) ព្រោះកាលពោលតាមសម្បយោគន័យ បញ្ញានេះរមែងប្រកបក្នុងចិត្តដែលជាញាណសម្បយុត្តទាំងអស់ ចិត្តដែលជាញាណសម្បយុត្តនោះមានចេតសិកប្រកប ៣៨ ដូច្នោះ បញ្ញា-ចេតសិកនេះ ទើបមានចេតសិកប្រកប ៣៧ (វៀរខ្លួនឯង) ។

## គាថាសម្ដែងចំនួនចេតសិកដោយពិស្ដារ ៣៤២៦ ដួង

ឥត្ថំ ចិត្តាវិយុត្តានំ      សម្បយោគញ្ច សង្គហំ

ញត្វា ភេទំ យថាយោគំ   ចិត្តេន សមមុទ្ទិសេ ។

អ្នកសិក្សាទាំងឡាយ កាលយល់សម្បយោគន័យ និងសង្គហន័យរបស់ចេតសិកដែលប្រកបនឹងចិត្តជានិច្ច ដោយន័យដែលពោលមកហើយ រមែងសម្ដែងចំនួនចេតសិកស្មើនឹងចិត្តតាមសមគួរដែលប្រកបបាន ។

## អធិប្បាយ

គាថានេះសម្ដែងវិធីរាប់ចេតសិកដោយពិស្ដារ តាមសម្បយោគន័យ និងសង្គហន័យ មានសេចក្ដីថា ចេតសិកដួងណាប្រកបនឹងចិត្តបានប៉ុន្មានដួង ក៏រាប់ចេតសិកនោះថា មានចំនួនស្មើនឹងចំនួនចិត្តដែលចេតសិកនោះប្រកបបាន គឺ

**សព្វចិត្តសាធារណចេតសិក ៧ ដួង** ក្នុងមួយដួងៗ ប្រកបនឹងចិត្តបានទាំងអស់ ដូច្នោះ សព្វចិត្តសាធារណចេតសិកទាំង ៧ ដងនោះ ទើបមានចំនួនស្មើនឹងចិត្តទាំងអស់ គឺ មួយដួងៗ មាន ១២១ ដួង រួមសព្វចិត្តសាធារណចេតសិក ៧ ដួង ទើបមានចំនួនសព្វចិត្តសាធារណចេតសិកទាំងអស់ ៨៤៧ ដួង ។

***បកិណ្ណកចេតសិកទាំង ៦*** មានចំនួនរួមទាំងអស់ ២៨៨ គឺវិតក្កៈ ៥៥ វិចារៈ ៦៦ អធិមោក្ខៈ ១១០ វិរិយៈ ១០៥ បីតិ ៥១ ឆន្ទៈ ១០១ ។

រួមជា អញ្ញសមានចេតសិកទាំងអស់ ១៣៣៥ ដួង ។

***អកុសលចេតសិក ១៤*** មានចំនួនរួមទាំងអស់ ៨៣ គឺ មោចតុក្កៈ ២៨ លោភិកៈ ១៦ ទោចតុក្កៈ ៨ ថិទុកៈ ១០ វិចិកិច្ឆា ១ រួមជាអកុសលចេតសិកទាំងអស់ ៨៣ ដួង ។

សោភណចេតសិក ២៥ មានចំនួនរួមទាំងអស់ ២០០៨ ដួង គឺ សោភណសាធារណៈ ១៩ ក្នុងមួយដួងៗ ប្រកបនឹងសោភណចិត្តបានទាំងអស់ ៩១ ដួង ទើបមានចំនួន ១៧២៩, វិរតិ ៣ ក្នុងមួយដួងៗ ប្រកបនឹងចិត្តបាន ២៨ ដួង ទើបមានចំនួន ១៤៤, អប្បមញ្ញា ២ ក្នុងមួយដួងៗ ប្រកបនឹងចិត្តបាន ២៨ ទើបមានចំនួន ៥៦, បញ្ញាប្រកបនឹងចិត្ត ៧៩ ទើបមានចំនួន ៧៩ រួមជាសោភណចេតសិកទាំងអស់ ២០០៨ ដួង ។

រួមជាចេតសិកដែលមានទាំងអស់ ៣៤២៦ ដួង ។

ចប់បរិច្ឆេទទី ២ ។



ពួកជនណាមិនមានសេចក្តីសន្សំ ពួកជនណាកំណត់ដឹងភោជនហើយ

ជនណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ

ជាគោចរ គតិគឺដំណើររបស់ពួកជននោះៗ គេកម្រដឹងបាន

ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ